


សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights


# ការអភិវឌ្ឍ លើទាសភាព

## “ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ នៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា”


របាយការណ៍ចេញ
ខែធ្នូ ឆ្នាំ២០១៦

# ការអភិវឌ្ឍ លើទាសភាព

## “ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ នៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា”

របាយការណ៍ចេញខែធ្នូ ឆ្នាំ២០១៦

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅ តាមសាខាទូទាំង ១៣ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តិ ដោយបុគ្គលអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**

ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានាៈ**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ**

អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


| | |
|---|---|
| សេចក្តីផ្តើម | ទំព័រ១ |
| វិធីសាស្រ្តស្រាវជ្រាវ | ទំព័រ២ |
| លទ្ធផលនៃការស្រាវជ្រាវ | ទំព័រ៤ |
| ការបញ្ចាំខ្លួនដោះបំណុល | ៤ |
| ទំនាក់ទំនងរវាងម្ចាស់សិប្បកម្ម និងកម្មករ | ៦ |
| ពលកម្មកុមារ | ៧ |
| ស្ថានភាពនៅក្នុងសិប្បកម្មផលិតឥដ្ឋ | ១៤ |
| ការរងរបួស | ១៤ |
| ច្បាប់ស្តីពីការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ | ទំព័រ១៧ |
| ច្បាប់ស្តីពីការជួញដូរ | ១៧ |
| ច្បាប់ស្តីពីការងារ | ១៨ |
| និទ្ទណ្ឌភាព | ១៩ |
| សេចក្តីសង្ខេប | ទំព័រ២២ |
| អនុសាសន៍ | ទំព័រ២៣ |




ក្មេងប្រុសអូសរទេះផ្ទុកឥដ្ឋឆៅមិនទាន់ដុត



ទិដ្ឋភាពសិប្បកម្មផលិតឥដ្ឋ និងកន្លែងស្នាក់នៅរបស់កម្មករ

# សេចក្ដីផ្ដើម

ក្នុងរយៈពេល ២០ឆ្នាំនេះ ប្រទេសកម្ពុជាមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចជាបន្ត បន្ទាប់ ហើយជាលទ្ធផលវិស័យសំណង់នៅកម្ពុជា កំពុងមានការកើនឡើងយ៉ាងខ្លាំង។ ទីក្រុងធំៗបំផុតដូចជា រាជធានីភ្នំពេញ ក្រុងព្រះសីហនុ និងក្រុងសៀមរាប មានការពង្រីកជាបន្តបន្ទាប់តាមរយៈការសាងសង់នូវអគារការិយាល័យ រោងចក្រ អគារខុនដូរ សំណង់ផ្ទះ សណ្ឋាគារ និងផ្សារទំនើបជាដើម[១]។ គម្រោងទាំងនោះត្រូវការឥដ្ឋចំនួនច្រើនហើយមានសិប្បកម្មផលិតឥដ្ឋក្នុងស្រុកជាច្រើន កំពុងតែត្រូវបានបង្កើតឡើងដើម្បីផ្គត់ផ្គង់ឥដ្ឋដល់គម្រោងទាំងអស់នោះ។ សិប្បកម្មទាំងនោះ ពឹងផ្អែកទៅលើកម្លាំងពលកម្មរបស់ទាសករសម័យថ្មី គឺសំដៅលើគ្រួសាររបស់មនុស្សពេញវ័យនិងកុមារជាច្រើនជំនាន់ ដែលត្រូវបញ្ចាំខ្លួននៅក្នុងសិប្បកម្មផលិតឥដ្ឋ ដើម្បីធ្វើការដោះបំណុល។

ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារជាប្រភេទការងារខុសច្បាប់ យោងតាមច្បាប់របស់កម្ពុជា និងសន្ធិសញ្ញាអន្តរជាតិជាច្រើនទៀត ដែលកម្ពុជាជារដ្ឋភាគី ប៉ុន្តែ ការអនុវត្តការងារទាំងនេះកំពុងមានភាពរីកដុះដាលនៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា។ របាយការណ៍នេះបានធ្វើឡើងដោយផ្អែកលើការស្រាវជ្រាវនៅតាមសិប្បកម្មផលិតឥដ្ឋ ដែលស្ថិតនៅភាគខាងជើងនៃរាជធានីភ្នំពេញ និងខេត្ត ត្បូងឃ្មុំ។ ការស្រាវជ្រាវនេះបង្ហាញថា ការបញ្ចាំខ្លួនដោះបំណុលជាមធ្យោបាយ ដែលត្រូវបានប្រើប្រាស់ជាទូទៅដោយម្ចាស់សិប្បកម្ម ដើម្បីទទួលបាននូវកម្លាំងពលកម្មរយៈពេលយូរ មានតម្លៃថោក និងចេះស្ដាប់បង្គាប់។ កុមារត្រូវបានបង្ខំជាញឹកញាប់ឲ្យជួយការងាររបស់ឪពុកម្ដាយនៅសិប្បកម្មទាំងនោះ ដោយសារតែប្រាក់ឈ្នួលពលកម្មទាប ហើយប្រព័ន្ធនៃការផ្ដល់ប្រាក់ឈ្នួលពលកម្មត្រូវគិតតាមចំនួនផលិតផល។ លក្ខខណ្ឌការងារនៅក្នុងសិប្បកម្មផលិតឥដ្ឋគឺប្រកបដោយគ្រោះថ្នាក់ហើយកន្លែងស្នាក់នៅរបស់កម្មករគ្មានអនាម័យ និងមិនមានអ្វីច្រើននោះទេ។ គ្រោះថ្នាក់កើតឡើងជាញឹកញាប់ ហើយក្នុងករណីខ្លះ មានអ្នករងរបួសធ្ងន់ធ្ងរដាច់អវយវៈ និងរហូតដល់បាត់បង់អាយុជីវិតក៏មានផងដែរ។

សិប្បកម្មផលិតឥដ្ឋភាគច្រើន ដែលត្រូវបានស្រាវជ្រាវនៅក្នុងរបាយការណ៍នេះ គឺមានភាពងាយស្រួលក្នុងការស្វែងរកសម្រាប់អ្នកធ្វើដំណើរចេញ ពីរាជធានីភ្នំពេញ ហើយសិប្បកម្មទាំងនោះ ងាយនឹងមើលឃើញពីលើផ្លូវជាតិសំខាន់ៗ។ នៅគ្រប់ករណីទាំងអស់ ប៉ុស្ដិ៍នគរបាលមូលដ្ឋាននិងអាជ្ញាធរឃុំ គឺស្ថិតនៅក្បែរនោះ។ ការកេងប្រវ័ញ្ចដែលធ្វើឡើងដោយម្ចាស់សិប្បកម្មផលិតឥដ្ឋ និងលក្ខខណ្ឌនៅទីនោះ គឺមិនពិបាកក្នុងការលាតត្រដាងនោះទេ ហើយបុគ្គលដែលទទួលខុសត្រូវចំពោះការអនុវត្តច្បាប់ក៏បានដឹងយ៉ាងច្បាស់ហើយដែរ។ ប៉ុន្តែសិប្បកម្មទាំងនោះ

[១] យោងតាមធនាគារពិភពលោក វិស័យសំណង់ និងអចលនទ្រព្យ បានរួមចំណែកច្រើនជាងគេ ចំពោះការលូតលាស់ទិន្នផល ក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ២០១៤ និងឆមាសទី១នៃឆ្នាំ២០១៥។ ធនាគារពិភពលោក, បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែតុលា ឆ្នាំ២០១៥, http://documents.worldbank.org/curated/en/115911468188931886/pdf/100537-WP-Box393233B-PUBLIC-Final-October-2015-CEU-report-English-reduce-size.pdf.

នៅតែអាចដំណើរការបានដោយគ្មានឧបសគ្គអ្វីឡើយ។ ការមិនយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរ និងកង្វះឆន្ទៈពីសំណាក់មន្ត្រីអនុវត្តច្បាប់ អំពើពុករលួយនិងភាពអស់ជម្រើសរបស់ប្រជាពលរដ្ឋក្រីក្របំផុត ក្នុងការផ្គត់ផ្គង់ជីវភាពមានន័យថាច្បាប់មិនត្រូវបានអនុវត្ត ហើយម្ចាស់សិប្បកម្មមិនប្រឈមនឹងទណ្ឌកម្មអ្វីទាំងអស់។

រាជរដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចក្នុងការបញ្ចប់ការបញ្ចាំខ្លួនដោះបំណុលនិងពលកម្មកុមារ ហើយការបញ្ចប់បញ្ហានេះគឺស្ថិតនៅក្រោមអំណាចរបស់អាជ្ញាធរផងដែរ។ រាជរដ្ឋាភិបាលអាចអនុវត្តវិធានការបន្ទាន់និងរយៈពេលយូរ ដោយមានការជួយជ្រោមជ្រែងពីសំណាក់អតិថិជនទិញឥដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីសម្រេចបាននូវគោលដៅនេះ។ នៅចុងបញ្ចប់នៃរបាយការណ៍នេះក៏មានផ្ដល់អនុសាសន៍មួយចំនួនជូនរាជរដ្ឋាភិបាលហើយប្រសិនបើមានការអនុវត្តតាម នោះធ្វើឲ្យរាជរដ្ឋាភិបាលអាចសម្រេចបាននូវការលុបបំបាត់ការកេងប្រវ័ញ្ច និងការងារប្រកបដោយគ្រោះថ្នាក់ទាំងនេះ។

# វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវនៅក្នុងរបាយការណ៍នេះ ត្រូវបានធ្វើឡើងជាចំបងនៅក្នុងសិប្បកម្មផលិតឥដ្ឋមួយចំនួន ដែលស្ថិតនៅជាយភាគខាងជើងនៃរាជធានីភ្នំពេញ និងក្នុងខេត្តកណ្ដាល តាមបណ្ដោយផ្លូវជាតិលេខ៥ និងផ្លូវជាតិលេខ៦អា។ ទីតាំងនេះត្រូវបានជ្រើសរើសដោយសារភាពងាយស្រួលក្នុងការធ្វើដំណើរសម្រាប់អ្នកស្រាវជ្រាវ និងដោយសារវាស្ថិតនៅជិតរាជធានីភ្នំពេញ (ទីក្រុងធំជាងគេ និងមានការរីកចម្រើនជាងគេនៅកម្ពុជា) មានន័យថាវាប្រហែលជាតំបន់ផលិតឥដ្ឋធំជាងគេនៅកម្ពុជាផងដែរ។

អង្គការ លីកាដូ បានកំណត់និងជ្រើសរើសតំបន់សិប្បកម្មផលិតឥដ្ឋចំនួន១១ដើម្បីធ្វើការស្រាវជ្រាវ ដែលតំបន់ខ្លះមានសិប្បកម្មផលិតឥដ្ឋចំនួន ១ ឬ ២ តែប៉ុណ្ណោះ ហើយទីតាំងដទៃទៀតមានសិប្បកម្មផលិតឥដ្ឋច្រើន រហូតដល់ ៣៩ ក្នុងមួយតំបន់ (សូមមេត្តាមើលផែនទីនៅទំព័រកណ្ដាលនៃរបាយការណ៍)[២]។ សិប្បកម្មទាំងនោះមានទំហំខុសគ្នា ដោយសារសិប្បកម្មខ្លះមានចំនួនកម្មករតិច គឺត្រឹមតែ ៣-៤ គ្រួសារ ខណៈដែលសិប្បកម្មខ្លះទៀតមានចំនួនកម្មកររហូតដល់ ២០-៣០ គ្រួសារឯណោះ។ នៅគ្រប់សិប្បកម្មផលិតឥដ្ឋទាំងអស់ កម្មកររស់នៅក្នុងខ្ទមដែលស្ថិតនៅក្នុងបរិវេណនៃសិប្បកម្មទាំងនោះ។ ចំនួនគ្រួសារសរុបនៅក្នុងតំបន់ ដែលត្រូវបានជ្រើសរើសដើម្បីធ្វើការស្រាវជ្រាវនេះ គឺមានភាពលំបាកក្នុងការរាប់ឲ្យបានច្បាស់ ប៉ុន្តែប្រាកដណាស់ថា កម្មករមានចំនួនរាប់ពាន់គ្រួសារ។

ក្នុងអំឡុងខែមិថុនា និងខែសីហា ឆ្នាំ២០១៦ បុគ្គលិកអង្គការលីកាដូ បានចុះទៅស្រាវជ្រាវនៅក្នុងតំបន់នីមួយៗ ហើយយើងបានធ្វើការសម្ភាសជាលក្ខណៈបុគ្គល ជាមួយកម្មករសិប្បកម្មផលិតឥដ្ឋទាំងនោះ នៅពេលដែលអាចធ្វើទៅរួច។ ក្នុងករណីផ្សេងទៀត ព័ត៌មានត្រូវបានប្រមូលតាមរយៈការសម្ភាសជាក្រុមដោយមានទាំងកុមារ និងមនុស្សពេញវ័យផងដែរ។ ជាលទ្ធផល បុគ្គលិកអង្គការលីកាដូបានសម្ភាសកម្មករប្រមាណ ៥០នាក់ ក្នុងអំឡុងពេលនោះ។ ការស្រាវជ្រាវបឋមក៏ធ្លាប់បានធ្វើឡើងនៅឆមាសទី១នៃឆ្នាំ២០១៥ នៅក្នុងសិប្បកម្មផលិតឥដ្ឋក្នុងឃុំមៀន ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ និងក្នុងឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ នាពេលនោះ កុមារចំនួន ៤ នាក់និងមនុស្សពេញវ័យចំនួន៤ នាក់ត្រូវបានសម្ភាសនៅក្នុងតំបន់នីមួយៗ ដែលនាំឲ្យចំនួនសរុបនៃអ្នកដែលបានផ្ដល់ការសម្ភាសមាន ១៦នាក់។

ទោះបីជាការសម្ភាសជាលក្ខណៈបុគ្គលឯកជនមានសារសំខាន់ខ្លាំង សម្រាប់ការសិក្សាស្រាវជ្រាវបែបនេះក៏ដោយ ប៉ុន្តែវិធីសាស្ត្រនៃការប្រមូលព័ត៌មានត្រូវតែមានការបត់បែនទៅតាមលក្ខខណ្ឌនៅក្នុងសិប្បកម្ម និងស្ថានការណ៍នៃការចុះធ្វើការស្រាវជ្រាវនោះ។ សិប្បកម្មផលិតឥដ្ឋភាគច្រើន មិនមានកន្លែងដើម្បីធ្វើការសម្ភាសជាលក្ខណៈបុគ្គលឯកជនទេ ហើយអំឡុងពេលនៃការចុះធ្វើការស្រាវជ្រាវភាគច្រើន ខ្វះពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើការសម្ភាស ដោយសារតែកម្មករត្រូវត្រឡប់ចូលទៅធ្វើការវិញបន្ទាប់ពីការសម្រាកទទួលទានអាហារថ្ងៃត្រង់រួចនោះ។ នៅក្នុងការស្រាវជ្រាវ មិនមានការជ្រើសរើសអ្នកផ្ដល់ការសម្ភាសតាមបែបផ្លូវការនោះទេ ផ្ទុយទៅវិញការសម្ភាសត្រូវបានធ្វើឡើងតែជាមួយកម្មករណាដែលមានពេលវេលានិងចង់ផ្ដល់ការសម្ភាសតែប៉ុណ្ណោះ។ គួរកត់សម្គាល់ផងដែរថា ក្នុងករណីខ្លះម្ចាស់សិប្បកម្មបានបង្កការលំបាកក្នុងការជួបសម្ភាសជាមួយកម្មករ ឬដើរមកជិតនៅពេលដែលបុគ្គលិកអង្គការលីកាដូព្យាយាមនិយាយទៅកាន់កម្មករ។

[២] ចំនួនក្នុងទីតាំងនីមួយៗប្រហែលជាមិនច្បាស់លាស់។ បុគ្គលិកអង្គការលីកាដូ រាប់ចំនួនសិប្បកម្មផលិតឥដ្ឋដែលពួកគាត់បានឃើញ ហើយក្នុងករណីខ្លះ បញ្ជាក់តួលេខនេះជាមួយអាជ្ញាធរឃុំ។

នៅក្នុងសិប្បកម្មផលិតឥដ្ឋមួយនោះមានកម្មករភាគច្រើនព្យាយាមលាក់ខ្លួន ហើយមិននិយាយជាមួយបុគ្គលិកអង្គការលីកាដូនោះទេ។ កម្មករម្នាក់បានពន្យល់ថា ម្ចាស់សិប្បកម្មបានប្រាប់ពួកគាត់ឲ្យធ្វើបែបនេះ ប្រសិនបើមានបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចុះមកកាន់ទីនោះ។

កិច្ចសម្ភាសនិងការពិភាក្សាជាក្រុមបានលើកឡើងពីប្រធានបទជាច្រើនដូចជា ព័ត៌មានលំអិតអំពីជីវិតរស់នៅប្រចាំថ្ងៃនិងការងាររបស់កម្មករ ស្ថានភាពហិរញ្ញវត្ថុនិងចំនួនទឹកប្រាក់ដែលពួកគាត់ឬគ្រួសាររបស់ពួកគាត់ជំពាក់ម្ចាស់សិប្បកម្ម ព័ត៌មានទាក់ទងនឹងដើមហេតុដែលនាំឲ្យពួកគាត់មកធ្វើការនៅសិប្បកម្មផលិតឥដ្ឋ ការអនុវត្តកិច្ចសន្យាការងារ ការប្រើប្រាស់ពលកម្មកុមារ ការទទួលបានការសិក្សាអប់រំ និងគ្រោះថ្នាក់បង្កឡើងដោយគ្រឿងម៉ាស៊ីនជាដើម។

នៅក្នុងសិប្បកម្មផលិតឥដ្ឋមួយនោះមានកម្មករភាគច្រើនព្យាយាមលាក់ខ្លួន ហើយមិននិយាយជាមួយបុគ្គលិកអង្គការលីកាដូនោះទេ។ កម្មករម្នាក់បានពន្យល់ថា ម្ចាស់សិប្បកម្មបានប្រាប់ពួកគាត់ឲ្យធ្វើបែបនេះ ប្រសិនបើមាន បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលចុះមកកាន់ទីនោះ។

បុគ្គលិកអង្គការលីកាដូ ក៏បានជួបពិភាក្សាជាមួយមេឃុំចំនួនពីរនាក់ និងមន្ត្រីនគរបាលម្នាក់។ ការជួបពិភាក្សានោះ មិនមែនជាការជួបសម្ភាសដែលមានការរៀបចំសំណួរល្អិតល្អន់នោះទេ ប៉ុន្តែប្រធានបទមួយចំនួនត្រូវបានលើកឡើងនៅក្នុងជំនួបពិភាក្សានោះដូចជា ចំនួនសិប្បកម្មផលិតឥដ្ឋ ចំនួនគ្រួសារនៅក្នុងឃុំ ពលកម្មកុមារនៅក្នុងសិប្បកម្មផលិតឥដ្ឋ ការទទួលបានការសិក្សាអប់រំបំណុលរបស់កម្មករ និងគ្រោះថ្នាក់ការងារនៅក្នុងសិប្បកម្មទាំងនោះផងដែរ។

នៅក្នុងការស្រាវជ្រាវចំនួនពីរលើកនេះ បុគ្គលិកអង្គការលីកាដូ បានចុះទៅកាន់សិប្បកម្មផលិតឥដ្ឋនៅទូទាំងប្រទេស ហើយបានជួបពិភាក្សាជាមួយកម្មករដែលធ្វើការនៅទីនោះនិងអាជ្ញាធរមូលដ្ឋានជាច្រើនលើកក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ បទពិសោធន៍និងព័ត៌មានដែលទទួលបានកន្លងមកនេះ បានគាំទ្រនិងរួមចំណែកជាច្រើនទៅក្នុងលទ្ធផលនៃរបាយការណ៍នេះ។

ទំហំផលិតកម្ម នៃសិប្បកម្មផលិតឥដ្ឋ នៅទូទាំងប្រទេសកម្ពុជាមិនត្រូវបានដឹងច្បាស់នោះទេ ប៉ុន្តែយើងឃើញសិប្បកម្មផលិតឥដ្ឋមានស្ទើរគ្រប់ខេត្ត-ក្រុង នេះមានន័យថាកម្លាំងពលកម្មនៅទូទាំងប្រទេសមានចំនួនរាប់ម៉ឺននាក់។ ការប្រៀបធៀបនៅក្នុងរបាយការណ៍នេះគឺយោងទៅលើលទ្ធផលនៃការស្រាវជ្រាវ នៅក្នុងតំបន់ផលិតឥដ្ឋចំនួនពីរតែប៉ុណ្ណោះហើយតំបន់ទាំងនេះក៏មានចំនួនសិប្បកម្មផលិតឥដ្ឋនិងកម្មករតិចដែរ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ព័ត៌មានដែលទទួលបានពីកម្មករទាំងនោះមានភាពស៊ីចង្វាក់គ្នាយ៉ាងខ្លាំង ពាក់ព័ន្ធនឹងការបញ្ចាំខ្លួនដោះបំណុល លក្ខខណ្ឌការងារ ការអនុវត្តកិច្ចសន្យាការងារ និងពលកម្មកុមារជាដើម។ លើសពីនេះទៅទៀត ព័ត៌មានទាំងនេះមានភាពស៊ីចង្វាក់គ្នាជាមួយនឹងព័ត៌មាន និងបទពិសោធន៍ដែលបុគ្គលិកអង្គការលីកាដូ ទទួលបានពីតំបន់ដទៃទៀតនៃប្រទេសកម្ពុជា។ នេះបង្ហាញថា របាយការណ៍នេះមានភាពត្រឹមត្រូវសម្រាប់តំបន់នៃការស្រាវជ្រាវទាំងពីរ ហើយក៏ប្រហែលជាអាចឆ្លុះបញ្ចាំងបាន ពីស្ថានភាពនៅក្នុងប្រទេសកម្ពុជាទាំងមូលផងដែរ។



ក្មេងប្រុសតូចទៅតាមឪពុកដែលកំពុងធ្វើការជីកដីឥដ្ឋ

## ការបញ្ចាំខ្លួនដោះបំណុល

ការបញ្ចាំខ្លួនដោះបំណុល គឺជាស្ថានភាពមួយដែលកើតមានឡើង នៅពេលកម្លាំងពលកម្មរបស់មនុស្សម្នាក់ត្រូវបានប្រើប្រាស់ដើម្បីធ្វើការទូទាត់សងបំណុល។ ជាទូទៅ កម្មករដែលធ្វើការងារដើម្បីដោះបំណុលទទួលបានប្រាក់កម្រៃទាបយ៉ាងខ្លាំង ដែលជារឿយៗនាំឲ្យពួកគាត់ជំពាក់បំណុលកាន់តែច្រើន ហើយគ្មានលទ្ធភាពសងបំណុលទាំងនោះវិញទេ។ ពួកគាត់អាចប្រឈមនឹងការកេងប្រវ័ញ្ចពលកម្ម ដោយសារតែការពឹងផ្អែកលើម្ចាស់បំណុល ហើយមានកម្មករជាច្រើននាក់ត្រូវបានបង្ខំឲ្យធ្វើការនៅក្នុងលក្ខខណ្ឌការងារ ដែលប្រកបដោយគ្រោះថ្នាក់ និងមិនសមរម្យ។ ការបញ្ចាំខ្លួនដោះបំណុលត្រូវបានច្បាប់អន្តរជាតិចាត់ទុកថា ជាការអនុវត្តស្រដៀងគ្នាទៅនឹងទាសភាព[៣] ហើយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ស្តីពីទម្រង់ទាសភាពសម័យទំនើបក៏បានយល់ថា នេះជាទម្រង់មួយនៃទាសភាពសម័យថ្មីផងដែរ[៤]។

កម្មករទាំងអស់ ដែលបានផ្ដល់ការសម្ភាសនៅក្នុងការស្រាវជ្រាវនេះបានលើកឡើងថា ពួកគាត់ជំពាក់ប្រាក់ម្ចាស់សិប្បកម្មផលិតឥដ្ឋ។ ប្រាក់បំណុលទាបបំផុតដែលបានរាយការណ៍មានចំនួន ១.០០០ ដុល្លារ ប៉ុន្តែពួកគាត់ភាគច្រើនជំពាក់ប្រាក់ម្ចាស់សិប្បកម្ម ចន្លោះពី ២.០០០ ទៅ ៣.០០០ ដុល្លារ ហើយកម្មករម្នាក់បានឲ្យដឹងថាគាត់ជំពាក់ប្រាក់ម្ចាស់សិប្បកម្មចំនួន ៦.០០០ ដុល្លារ។ កម្មករទាំងអស់ដែលបានផ្ដល់ការសម្ភាស បាននិយាយថា គ្រួសារទាំងអស់ផ្សេងទៀត នៅក្នុងសិប្បកម្មផលិតឥដ្ឋរបស់ពួកគាត់ជំពាក់ប្រាក់ម្ចាស់សិប្បកម្មក្នុងចំនួនប្រហាក់ប្រហែលគ្នា។

កម្មករទាំងអស់ដែលបានផ្ដល់ការសម្ភាស បានប្រាប់នូវរឿងរ៉ាវស្រដៀងគ្នា អំពីហេតុផលដែលធ្វើឲ្យពួកគាត់ជំពាក់បំណុលម្ចាស់សិប្បកម្មផលិតឥដ្ឋ។ ពួកគាត់ជាច្រើនបានរៀបរាប់ថា ដំបូង ពួកគាត់ធ្លាក់ខ្លួនជំពាក់ប្រាក់ម្ចាស់សិប្បកម្ម ដោយសារតែពួកគាត់ត្រូវទូទាត់ចំពោះថ្លៃចំណាយលើការព្យាបាល ដែលបណ្ដាលមកពីការមានផ្ទៃពោះ ឬការឈឺស្កាត់នៅក្នុងគ្រួសារ។ ពួកគាត់មួយចំនួនទៀតបានខ្ចីប្រាក់ដើម្បីទៅទិញគ្រាប់ពូជ ឬសត្វពាហនៈ ហើយគ្មានលទ្ធភាពសងវិញដោយសារតែទទួលបានទិន្នផលមិនល្អ។ អ្នកខ្លះទៀតបានលើកឡើងថា ពួកគាត់បានខ្ចីប្រាក់ដោយសារតែភាពក្រលំបាក ហើយមិនមានដីសម្រាប់បង្កបង្កើនផល និងគ្មានមធ្យោបាយក្នុងការរកប្រាក់។

ពួកគាត់ជាច្រើនបានរៀបរាប់ថា ដំបូង ពួកគាត់ធ្លាក់ខ្លួនជំពាក់ប្រាក់ម្ចាស់សិប្បកម្មដោយសារតែពួកគាត់ត្រូវទូទាត់ចំពោះថ្លៃចំណាយលើការព្យាបាលដែលបណ្ដាលមកពីការមានផ្ទៃពោះ ឬការឈឺស្កាត់នៅក្នុងគ្រួសារ។ ពួកគាត់មួយចំនួនទៀតបានខ្ចីប្រាក់ដើម្បីយកទៅទិញគ្រាប់ពូជ ឬសត្វពាហនៈ ហើយគ្មានលទ្ធភាពសងវិញដោយសារតែទទួលបានទិន្នផលមិនល្អ។

ករណីភាគច្រើន ពួកគាត់បានផ្ដើមខ្ចីប្រាក់ពីធនាគារ ឬអ្នកផ្ដល់ប្រាក់កម្ចីផ្សេងទៀតនៅក្នុង មូលដ្ឋានរបស់ពួកគាត់។ នៅពេលពួកគាត់មិនមានលទ្ធភាពសងប្រាក់នោះវិញ ឬត្រូវការខ្ចីប្រាក់បន្ថែមទៀត ពួកគាត់ត្រូវផ្ទេរបំណុលនោះទៅឲ្យម្ចាស់សិប្បកម្មផលិតឥដ្ឋ ដើម្បីសងជំនួស ហើយសន្យាធ្វើការឲ្យម្ចាស់សិប្បកម្មនោះដើម្បីសងបំណុលដែលពួកគាត់បានជំពាក់។ នេះជាជម្រើសដ៏ទាក់ទាញសម្រាប់ពួកគាត់ ដោយសារម្ចាស់សិប្បកម្មមិនគិតការប្រាក់លើប្រាក់បំណុលនោះទេ ហើយផ្ដល់កន្លែងស្នាក់នៅក្នុងបរិវេណសិប្បកម្មថែមទៀត។ កម្មករជាច្រើនដែលបានផ្ដល់ការសម្ភាស បានធ្វើចំណាកស្រុកមកធ្វើការនៅសិប្បកម្មផលិតឥដ្ឋ។ នៅក្នុងសិប្បកម្មផលិតឥដ្ឋក្បែររាជធានីភ្នំពេញ មានកម្មករជាច្រើនគ្រួសារមកពី ខេត្តព្រៃវែង កំពង់ធំ កំពង់ចាម តាកែវ និងខេត្តស្វាយរៀង។ ចំពោះសិប្បកម្មផលិតឥដ្ឋនៅខេត្តត្បូងឃ្មុំវិញ កម្មករភាគច្រើនជាអ្នកខេត្តត្បូងឃ្មុំ ដូចនេះពួកគាត់មិនបានធ្វើចំណាកស្រុក

[៣] មាត្រា ១ (ក) នៃអនុសញ្ញាបំពេញបន្ថែមស្តីពីការលុបបំបាត់ចោលនូវទាសភាព ការជួញដូរទាសភាព ស្ថាប័ន និងការអនុវត្តស្រដៀងទាសភាព ឆ្នាំ១៩៥៦ អង្គការសហប្រជាជាតិ, http://www.ohchr.org/EN/ProfessionalInterest/Pages/SupplementaryConventionAbolitionOfSlavery.aspx.

[៤] ក្នុងខែកញ្ញា ឆ្នាំ២០១៦ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ បានចាត់ទុកការងារដោះបំណុល ថាជា "ទម្រង់មួយនៃទម្រង់ដែលកំពុងរីករាលដាលបំផុតនៃទាសភាពសម័យថ្មី", http://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=20504&LangID=E. សូមមើលផងដែរនូវរបាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្តីពីទម្រង់បច្ចុប្បន្ននៃការងារបែបទាសភាព ដោយរួមទាំងមូលហេតុ និងលទ្ធផលរបស់វាផងដែរ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៦, https://documents-dds-ny.un.org/doc/UNDOC/GEN/G16/142/67/PDF/G1614267.pdf?OpenElement

ឆ្ងាយនោះទេ។ ដំបូងឡើយ កម្មករចំណាកស្រុកទាំងនោះបានដឹងព័ត៌មានអំពីការងារនៅសិប្បកម្ម ផលិតឥដ្ឋពីអ្នកភូមិផ្សេងទៀត ដែលកំពុងធ្វើការនៅសិប្បកម្មផលិតឥដ្ឋ នៅពេលអ្នកភូមិទាំងនោះត្រឡប់ទៅស្រុកភូមិវិញ អំឡុងពេលឈប់សម្រាកនៃពិធីបុណ្យជាតិផ្សេងៗ។ ម្ចាស់សិប្បកម្មផលិតឥដ្ឋ បានប្រាប់ឲ្យកម្មករទាំងនោះជួយចែកចាយព័ត៌មានទៅអ្នកភូមិផ្សេងទៀត អំពីលទ្ធភាពក្នុងការខ្ចីប្រាក់ កន្លែងស្នាក់នៅ និងការងារនៅក្នុងសិប្បកម្មផលិតឥដ្ឋ ដើម្បីទាក់ទាញអ្នកភូមិផ្សេងទៀតឲ្យមកធ្វើការ។

ក្នុងចំណោមកម្មករទាំងអស់ ដែលបានផ្តល់ការសម្ភាស មិនមានកម្មករណាម្នាក់មានកិច្ចសន្យាការងារនោះទេ។ នៅពេលដែលសួរពីកិច្ចសន្យាការងារ ពួកគាត់លើកឡើងពីកិច្ចសន្យាខ្ចីប្រាក់ទៅវិញ ពីព្រោះពួកគាត់មានត្រឹមតែកិច្ចសន្យាខ្ចីប្រាក់ ដែលជាឯកសារភស្តុតាងតែមួយគត់ក្នុងការបញ្ជាក់ទំនាក់ទំនងរវាងពួកគាត់ និងម្ចាស់សិប្បកម្ម។ ពួកគាត់ទាំងអស់មិនមានប្រាក់បៀវត្សរ៍ប្រចាំខែនោះទេ ប៉ុន្តែពួកគាត់ទទួលបានប្រាក់ឈ្នួលទៅតាមចំនួនផលិតផល។ ចំនួនប្រាក់ឈ្នួលប្រចាំថ្ងៃដែលពួកគាត់ទទួលបានមានចំនួនខុសៗគ្នា អាស្រ័យទៅលើប្រភេទការងារនៃចង្វាក់ផលិតកម្ម ដែលពួកគាត់បានធ្វើ និងចំនួនសមាជិកគ្រួសារ ដែលចូលរួមជួយក្នុងការងារនោះ។ ចំនួនប្រាក់ឈ្នួលប្រចាំថ្ងៃដែលពួកគាត់ទទួលបានគឺមានចន្លោះពី ២.៥ដុល្លារ ទៅ ១០ដុល្លារ។ គ្រួសារភាគច្រើនយល់ឃើញថា ប្រាក់ឈ្នួលនេះ គឺមិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅរបស់ពួកគាត់ទេ ដោយនេះមិនគិតពីការបង់រំលោះប្រាក់បំណុលរបស់ពួកគាត់ផង[៥]។ លើសពីនេះទៅទៀត ចំនួនប្រាក់ចំណូលប្រចាំថ្ងៃខាងលើនេះអាចរកបានតែក្នុងរដូវប្រាំងតែប៉ុណ្ណោះ (រដូវនេះចាប់ពីខែវិច្ឆិកាដល់ខែមេសា)។ ក្នុងរដូវវស្សាចាប់ពីខែឧសភាដល់ខែតុលា ឥដ្ឋហាលក្រស្ងួតហើយប្រាក់ចំណូលរបស់ពួកគាត់ធ្លាក់ចុះ។ ពួកគាត់មួយចំនួនបានរៀបរាប់ថាពួកគាត់ត្រូវបេះបន្លែនៅក្នុងព្រៃ ហើយយកទៅលក់នៅផ្សារ ដើម្បីជួយទ្រទ្រង់ជីវភាពគ្រួសារបន្ថែម។ ប៉ុន្តែក្នុងរដូវវស្សានេះ ពួកគាត់មានការលំបាកជាខ្លាំងក្នុងការទ្រទ្រង់ជីវភាពប្រចាំថ្ងៃ ហេតុនេះហើយទើបពួកគាត់ត្រូវខ្ចីប្រាក់បន្ថែមទៀតពីម្ចាស់សិប្បកម្ម ដើម្បីដោះទាល់ទម្រាំរដូវប្រាំងថ្មីមកដល់។ កម្មករខ្លះទៀតបានឲ្យដឹងថាម្ចាស់សិប្បកម្មមួយចំនួនបានផ្តល់ជាជំនួយផ្នែកសម្ភារៈផ្សេងទៀត។ ឧទាហរណ៍ដូចជា៖ ស្ត្រីម្នាក់បានមានប្រសាសន៍ថាម្ចាស់សិប្បកម្មរបស់គាត់បានទិញអង្ករទម្ងន់ ១០ គីឡូក្រាម ជាច្រើនចង់ក្នុងតម្លៃលក់ដុំដើម្បីចែកដល់កម្មករ។ ប៉ុន្តែថ្លៃ


ឥដ្ឋត្រូវបានយកទៅហាលថ្ងៃទុកមុនពេលយកទៅដុត

ទិញអង្ករនេះ ត្រូវបានបូកបញ្ចូលបន្ថែមទៅក្នុងចំនួនប្រាក់ដែលពួកគាត់បានជំពាក់ម្ចាស់សិប្បកម្មនោះ។ ក្នុងស្ថានភាពបែបនេះ ប្រាក់បំណុលរបស់កម្មករកើនឡើង ជារៀងរាល់ឆ្នាំ ហើយលទ្ធភាពរបស់ពួកគាត់ក្នុងការសងបំណុលវិញមានកាន់តែតិចទៅៗ។

ការចំណាយលើថ្លៃព្យាបាលជំងឺ គឺជាដើមហេតុចម្បង ដែលបណ្តាលឲ្យពួកគាត់ជំពាក់បំណុលកាន់តែច្រើនឡើង។ ស្ថានភាពការងារប្រកបដោយគ្រោះថ្នាក់និងលក្ខខណ្ឌនៃការរស់នៅមិនល្អនៅ ក្នុងសិប្បកម្មផលិតឥដ្ឋ មានន័យថា ការឈឺស្កាត់ ឬការរងរបួសកើតឡើងជាញឹកញាប់។ ការខ្វះការយល់ដឹងលើការពន្យារកំណើតឲ្យបានត្រឹមត្រូវក៏ជាបញ្ហាមួយដែរ ខណៈដែលស្ត្រីមួយចំនួនត្រូវ

[៥] យោងតាមមាត្រា ១០៨ នៃច្បាប់ស្តីពីការងារកម្ពុជា ប្រាក់ឈ្នួលសម្រាប់ការងារតាមបរិមាណផលិតផល ត្រូវគិតយ៉ាងណាឲ្យកម្មករនិយោជិតដែលមានការប៉ិនប្រសប់មធ្យមធ្វើការជាធម្មតាបានទទួលក្នុងថិរវេលាធ្វើការដដែល នូវប្រាក់ឈ្នួលយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលអប្បបរមា ដែលត្រូវធានា ហើយដែលកំណត់សម្រាប់កម្មការនិយោជិត។



ក្មេងប្រុសជំទង់បើកបររទេះដឹកឥដ្ឋឆៅដើម្បីយកទៅដុតក្នុងឡ

សម្រាលកូនរៀងរាល់១ឆ្នាំ ឬ ២ឆ្នាំម្តង។ ក្នុងករណីមួយនោះ ស្ត្រីម្នាក់បានមានប្រសាសន៍ថាគាត់បានទទួលការវះកាត់ចំនួនពីរដង ដើម្បីធានាសុវត្ថិភាពនៃការសម្រាលកូនពីរនាក់ចុងក្រោយរបស់គាត់ ដោយសារគាត់មិនអាចសម្រាលកូនតាមបែបធម្មជាតិបាន។ គាត់ត្រូវបានម្ចាស់សិប្បកម្មជួយរ៉ាប់រងបង់ថ្លៃវះកាត់ទាំងពីរលើក ប៉ុន្តែការចំណាយលើថ្លៃវះកាត់ជាង ៥០០ ដុល្លារ ក្នុងមួយលើកៗនោះត្រូវបានបូកបញ្ចូលបន្ថែមទៀត ទៅលើចំនួនទឹកប្រាក់ដែលគាត់បានជំពាក់ម្ចាស់សិប្បកម្ម ដែលធ្វើឲ្យប្រាក់បំណុលរបស់គាត់កើនឡើងជិត ២០០ ភាគរយ។

ករណីមួយចំនួនទៀតនៅពេលគ្រួសារកម្មករត្រូវការប្រាក់ច្រើនដោយបន្ទាន់ ហើយពេលនោះម្ចាស់សិប្បកម្មមិនចង់ផ្តល់ប្រាក់ឲ្យពួកគាត់ខ្ចីបន្ថែម ពួកគាត់ត្រូវប្តូរកន្លែងការងារទៅធ្វើឲ្យសិប្បកម្មផលិតឥដ្ឋផ្សេងទៀត។ ពួកគាត់ខ្ចីប្រាក់ពីម្ចាស់សិប្បកម្មថ្មី ក្នុងចំនួនមួយច្រើនជាងប្រាក់បំណុលដែលគាត់ជំពាក់ម្ចាស់សិប្បកម្មចាស់ ដើម្បីឲ្យពួកគាត់អាចសងប្រាក់បំណុលទៅម្ចាស់សិប្បកម្មចាស់ហើយអាចសល់ប្រាក់ ២០០ ឬ ៣០០ ដុល្លារផង។ កម្មករដែលបានផ្តល់ការសម្ភាសស្ទើរតែទាំងអស់ បានផ្លាស់ប្តូរកន្លែងធ្វើការយ៉ាងតិចណាស់ចំនួនពីរដង ដើម្បីឲ្យពួកគាត់អាចខ្ចីប្រាក់បន្ថែមទៀតបាន។ ស្ត្រីម្នាក់ដែលកំពុងជំពាក់ប្រាក់ម្ចាស់សិប្បកម្មចំនួន ៣.០០០ ដុល្លារ ធ្លាប់ធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋចំនួនដប់មកហើយ។

គ្រួសារកម្មករទាំងនោះ នឹងមិនអាចសងបំណុលអស់នោះទេ ដោយសារតែបំណុលរបស់ពួកគាត់មានការកើនឡើងជាបន្តបន្ទាប់ ហើយកូនចៅរបស់ពួកគាត់ជំនាន់ក្រោយ នឹងត្រូវទទួលរ៉ាប់រងសងប្រាក់បំណុលទាំងនោះបន្តទៅទៀត។ អំឡុងពេលនៃការស្រាវជ្រាវនេះបុគ្គលិកអង្គការលីកាដូ បានជួបជាមួយគ្រួសារកម្មករមួយចំនួនដែលបានរស់នៅ និងធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋ ៣ជំនាន់មកហើយ។ ប្រាក់បំណុលដំបូងត្រូវបានជំពាក់ដោយសមាជិកគ្រួសារជំនាន់មុន។

## ទំនាក់ទំនងរវាងម្ចាស់សិប្បកម្ម និងកម្មករ

ទោះបីជាពួកគាត់បាន ជួបប្រទះនូវការកេងប្រវ័ញ្ចនិងស្ថានភាពជីវិតដ៏លំបាក ប៉ុន្តែមានកម្មករតិចណាស់ដែលសម្តែងនូវការមិនសប្បាយចិត្ត ឬក៏ទទូចទាមទារឲ្យម្ចាស់សិប្បកម្ម ផ្តល់នូវលក្ខខណ្ឌការងារឬសិទ្ធិការងារ

ប្រសើរជាងមុន។ នេះហាក់ដូចជាមកពីពួកគាត់ចាត់ទុកម្ចាស់សិប្បកម្មជាម្ចាស់ជាជាងនយោជក ហើយចាត់ទុកខ្លួនឯងជាកូនចៅជាជាងបុគ្គលិក។ជាទូទៅចំណុចនេះត្រូវបានលើកឡើងដោយកម្មករ ដែលបានផ្តល់ការសម្ភាសថា ម្ចាស់សិប្បកម្មជាមនុស្សល្អពីព្រោះគាត់បានផ្តល់ប្រាក់កម្ចីដល់ពួកគាត់ដែលជួយឲ្យពួកគាត់ និងគ្រួសារអាចរស់រានបាន។ ហេតុដូច្នេះហើយបានជាពួកគាត់មានការពឹងផ្អែក និងដឹងគុណចំពោះម្ចាស់សិប្បកម្មទៅវិញ។

យោងតាមការសម្ភាសបង្ហាញថា ភាពពឹងផ្អែកដែលពួកគាត់មានទៅលើម្ចាស់សិប្បកម្មផលិតឥដ្ឋបានធ្វើឲ្យពួកគាត់មិនចាប់អារម្មណ៍ចំពោះការកេងប្រវ័ញ្ច ដែលពួកគាត់បានកំពុងជួបប្រទះ។ មិនមានកម្មករណាម្នាក់បង្ហាញនូវការមិនសប្បាយចិត្ត ចំពោះបញ្ហាប្រាក់ឈ្នួលទាប ឬស្ថានភាពការងារប្រកបដោយគ្រោះថ្នាក់ ឬស្ថាន-ភាពរស់នៅមិនសមរម្យនោះទេ។ ហើយក៏មិនមាននរណាម្នាក់បានត្អូញត្អែរថា ម្ចាស់សិប្បកម្មបានប្រើប្រាស់ប្រាក់បំណុលជាមធ្យោបាយ ក្នុងការបង្ខិតបង្ខំឲ្យពួកគាត់ធ្វើការងារនោះដែរ។ ផ្ទុយទៅវិញពួកគាត់ហាក់ដូចជាចាត់ទុករទង្វើទាំងនោះជាទឹកចិត្តមេត្តា ឬជាការជួយយកអាសារដែលត្រូវសងគុណទៅវិញ។

**មានកម្មករជាច្រើន បានរៀបរាប់ថា ម្ចាស់សិប្បកម្ម បានព្រមានហៅនគរបាល ហើយពួកគាត់អាចនឹង ត្រូវចាប់ខ្លួន ប្រសិនបើពួកគាត់ ព្យាយាមចាកចេញដោយ មិនសងប្រាក់ជំពាក់ម្ចាស់ សិប្បកម្មនោះវិញទេ។**

ភាពដឹងគុណនេះគឺត្រូវបានគួបផ្សំគ្នា និងជម្រុញបន្ថែមទៀតដោយការភ័យខ្លាច។ ដោយសារកម្មករសិប្ប-កម្មផលិតឥដ្ឋទាំងនោះគ្មានជម្រើសដទៃទៀត ក្នុងការទ្រទ្រង់ជីវភាពរស់នៅ ពួកគាត់ជាច្រើនមានការព្រួយបារម្ភចំពោះការបាត់បង់អត្ថប្រយោជន៍ដែលទទួលបាន ពីការរក្សាទំនាក់ទំនងជាមួយម្ចាស់សិប្បកម្ម ហេតុនេះហើយបានជាធ្វើឲ្យលទ្ធភាពរបស់អ្នកទាំងនោះក្នុងការតវ៉ាចំពោះការរំលោភបំពាន ឬការកេងប្រវ័ញ្ចមានកាន់តែតិចទៅៗ។ ចំពោះកម្មករនៅសិប្បកម្ម ដែលបានព្យាយាមលាក់ពួនពីបុគ្គលិកអង្គការលីកាដូ មានកម្មករម្នាក់ដែលមិនបានលាក់ពួនបានពន្យល់ប្រាប់ថា កម្មករដែលធ្វើការជាមួយគាត់ទាំងនោះមិនចង់ឲ្យអង្គការមិនមែនរដ្ឋាភិបាល ដឹងពីលក្ខខណ្ឌការងារនៅក្នុងសិប្បកម្មផលិតឥដ្ឋនោះទេដោយសារពួកគាត់មានការព្រួយបារម្ភថាសិប្បកម្មដែលពួកគាត់កំពុងធ្វើការអាចនឹងត្រូវបិទទ្វារហើយពួកគាត់នឹងត្រូវបាត់បង់ទីជម្រកនិងការងារ។ ការគំរាមកំហែងក៏ជាហេតុផលដែលធ្វើឲ្យមានការភ័យខ្លាច ដោយសារតែមានកម្មករជាច្រើនបានរៀបរាប់ថា ម្ចាស់សិប្បកម្មបានព្រមានហៅនគរបាលហើយពួកគាត់អាចនឹងត្រូវចាប់ខ្លួន ប្រសិនបើពួកគាត់ព្យាយាមចាកចេញ ដោយមិនសងប្រាក់ជំពាក់ម្ចាស់សិប្បកម្មនោះវិញទេ។

នេះហាក់បីដូចជា មិនមែនជាការគំរាមកំហែងលេងនោះទេ។ បុគ្គលិកអង្គការលីកាដូ បានជួយអន្តរាគមលើករណីមួយពាក់ព័ន្ធនឹងបុរសវ័យក្មេងម្នាក់ ដែលបានចាកចេញពីកន្លែងធ្វើការនៅសិប្បកម្មផលិតឥដ្ឋ ដោយសារតែម្ចាស់សិប្បកម្មនោះ បានរឹបអូសយកប្រាក់របស់គ្រួសារគាត់ទាំងអស់ដើម្បីទូទាត់បំណុលដែលធ្វើឲ្យពួកគាត់គ្មានប្រាក់ជាប់នឹងខ្លួនទាល់តែសោះ។ បុរសនោះបានទៅខ្ចីប្រាក់បន្ថែមពីម្ចាស់សិប្បកម្មផលិតឥដ្ឋមួយទៀត ដើម្បីផ្ញើមកឲ្យឪពុក ម្តាយរបស់គាត់ដែលកំពុងរស់នៅនិងធ្វើការនៅសិប្បកម្មចាស់។ ម្ចាស់សិប្បកម្មចាស់បានហៅមន្ត្រីនគរបាលស្រុក ឲ្យមកចាប់ខ្លួនឪពុកម្តាយរបស់គាត់យកទៅប៉ុស្តិ៍នគរបាលដើម្បីបង្ខំឲ្យបុរសនោះ ត្រឡប់មកវិញ។ អង្គការលីកាដូបានជួយអន្តរាគមហើយរយៈពេល ៣/៤ ម៉ោងក្រោយមក ឪពុកម្តាយរបស់បុរសនោះត្រូវបានដោះលែងមកវិញ ប៉ុន្តែករណីនេះបង្ហាញឲ្យឃើញថាមន្ត្រីនគរ-បាលមានចេតនា ក្នុងការប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីបម្រើប្រយោជន៍ម្ចាស់សិប្បកម្ម ហើយដាក់ពិន័យចំពោះកម្មករដែលមិនធ្វើតាមម្ចាស់សិប្បកម្ម។

## ពលកម្មកុមារ

ពលកម្មកុមារ មានច្រើននៅក្នុងសិប្បកម្មផលិតឥដ្ឋ។ កុមារទាំងអស់ដែលបានផ្តល់ការ សម្ភាសជាលក្ខណៈបុគ្គលបានរៀបរាប់ថា ពួកគេធ្វើការមួយផ្នែកនៅក្នុងសិប្បកម្មផលិតឥដ្ឋ ដែលជាកន្លែងពួកគាត់រស់នៅជាមួយឪពុកម្តាយ។ ពួកគាត់មានអាយុចន្លោះពី១៣ឆ្នាំទៅ១៥ឆ្នាំ ប៉ុន្តែអង្គការលីកាដូបានសង្កេតឃើញកុមារខ្លះមានអាយុត្រឹមតែ៩ឆ្នាំឬ១០ឆ្នាំតែប៉ុណ្ណោះ។ នៅតំបន់សិប្បកម្មផលិតឥដ្ឋក្នុងរាជធានីភ្នំពេញ ឪពុកម្តាយភាគច្រើនបានលើកឡើងថាទោះបីជាយ៉ាងណាក៏ដោយ ក៏កូនៗរបស់ពួកគាត់ បានជួយធ្វើការងារពួកគាត់ដើម្បីបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ។ នេះគឺជាកត្តាជម្រុញឲ្យកុមារធ្វើបែបនោះ ដោយសារតែប្រាក់ឈ្នួលត្រូវទូទាត់ទៅតាមចំនួនផលិតផល អញ្ចឹងហើយពេលណាគ្រួសារពួកគាត់ផលិតបានចំនួនឥដ្ឋច្រើន ពួកគាត់ក៏ទទួលបានចំណូលច្រើនដែរ។ ក្នុងករណីមួយចំនួនកុមារបាននិយាយថា ពួកគេជួយធ្វើការឪពុកម្តាយ ដើម្បីឲ្យគ្រួសាររបស់ពួកគេមាន



ក្មេងប្រុសពីរនាក់កំពុងរៀបឥដ្ឋនៅដាក់ហាលថ្ងៃ

## ករណីសិក្សា - បញ្ញា

បញ្ញាមានអាយុ៣៧ឆ្នាំ បានធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋអស់រយៈពេលជាង២០ឆ្នាំមកហើយ។ គាត់គ្មានផ្ទះឬដីនៅស្រុកកំណើតរបស់គាត់នោះទេ ហេតុនេះហើយ ទើបគាត់មានការលំបាកក្នុងការរស់នៅទីនោះ។ គាត់បានចាប់ផ្តើមធ្វើការនៅសិប្បកម្មផលិតឥដ្ឋ បន្ទាប់ពីគាត់បានខ្ចីប្រាក់ពីម្ចាស់សិប្បកម្មនោះ ដើម្បីយកទៅទូទាត់ថ្លៃចំណាយលើការព្យាបាលជំងឺកូនរបស់គាត់។ ប្រាក់កម្ចីនេះបានកើនឡើងរហូតដល់ ១.២០០ដុល្លារ បន្ទាប់ពីគាត់បានខ្ចីប្រាក់សម្រាប់ការទ្រទ្រង់ការចំណាយប្រចាំថ្ងៃបន្ថែមទៀត។ គាត់បានធ្វើការឲ្យសិប្បកម្មនោះរយៈពេល១៨ឆ្នាំ។ កាលពី៣ឆ្នាំមុន គាត់បានប្ដូរកន្លែងការងារមកធ្វើការឲ្យសិប្បកម្មផលិតឥដ្ឋបច្ចុប្បន្នដែលគាត់កំពុងធ្វើការ ហើយបានសុំឲ្យម្ចាស់សិប្បកម្មថ្មីនោះជួយសងប្រាក់ចំនួន១.២០០ដុល្លារ ដែលគាត់ជំពាក់ម្ចាស់សិប្បកម្មចាស់។ គាត់សប្បាយចិត្តក្នុងការចាកចេញពីសិប្បកម្មចាស់ពីព្រោះ ម្ចាស់សិប្បកម្មចាស់នោះធ្លាប់បានទាក់ទងទៅមន្ត្រីនគរបាលនៅពេលមានកម្មករណាម្នាក់ចង់ចាកចេញពីទីនោះ ហើយធ្វើការគុណបន្ថែមប្រាក់ជំពាក់គ្រប់ពេលដែលគាត់ចង់ធ្វើ។ គាត់មិនបានធ្វើកិច្ចសន្យាការងារជាមួយនឹងម្ចាស់សិប្បកម្មទេ ប៉ុន្តែគាត់ពិតជាបានផ្តិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់ នៅពេលដែលគាត់ចូលទៅធ្វើការនៅទីនោះ។ គាត់រៀបរាប់ថាម្ចាស់សិប្បកម្មបច្ចុប្បន្ន មានសណ្ដានចិត្តល្អ ពីព្រោះគាត់តែងបញ្ជូនកម្មករទៅមន្ទីរពេទ្យនៅពេលមានកម្មករណាម្នាក់មានជំងឺ។ គាត់ក៏ជួយរ៉ាប់រងការចំណាយលើថ្លៃទឹកប្រើប្រាស់កន្លែងស្នាក់នៅនិងថ្លៃអគ្គិសនីផងដែរ។ នៅសិប្បកម្មថ្មីនេះ បញ្ញាធ្វើការជាអ្នកកាប់ដី ដឹកដី និងជួយជួសជុលម៉ាស៊ីន។ បញ្ញាមានកូនចំនួន ៥នាក់ ហើយក្នុងនោះមាន៣នាក់បានទៅរៀន។ បន្ទាប់ពីការសិក្សា កូនៗរបស់គាត់ជួយជញ្ជូនឥដ្ឋចេញពីឡនិងដឹកឥដ្ឋទាំងនោះតាមរទេះ។ បញ្ញាលើកឡើងថាគាត់មិនបានបង្ខំកូនៗរបស់គាត់ឲ្យធ្វើការនោះទេ ប៉ុន្តែ គាត់បានសុំឲ្យកូនៗទាំងនោះជួយដើម្បីពន្លឿនការងារ ហើយដើម្បីឲ្យគាត់អាចផលិតឥដ្ឋបានគ្រប់គ្រាន់និងទទួលបានប្រាក់ឈ្នួលដែលគាត់ត្រូវការ។ បន្ទាប់ពីធ្វើការនៅសិប្បកម្មផលិតឥដ្ឋអស់រយៈពេលជាង២០ឆ្នាំមកបញ្ញាមានការធុញទ្រាន់ជាមួយនឹងការងារនេះ ហើយគាត់មិនចង់ឲ្យកូនរបស់គាត់មានជីវិតលំបាកដូចគាត់នោះទេ។

ប្រាក់ទិញម្ហូបអាហារ។ ឪពុកម្តាយទាំងអស់បានដឹងពីការងារគ្រោះថ្នាក់នៅក្នុងសិប្បកម្មផលិតឥដ្ឋ ហើយមិនចង់ឲ្យកូនៗរបស់ពួកគាត់ធ្វើការនៅទីនោះទេ ប៉ុន្តែពួកគាត់គ្មានជម្រើស។

ទោះបីជាមិនមានកុមារណាម្នាក់និយាយថា គាត់បំពេញគ្រប់កិច្ចការទាំងអស់នៅក្នុងសិប្បកម្ម ប៉ុន្តែវាច្បាស់ណាស់ថា កុមារទាំងនោះចូលរួមគ្រប់ដំណាក់កាលនៃដំណើរការផលិតឥដ្ឋ។ យ៉ាងតិចណាស់កុមារម្នាក់ក្នុងចំណោមកុមារដែលបានផ្តល់ការសម្ភាសនៅខេត្ត ត្បូងឃ្មុំ បាននិយាយថា គាត់បានបំពេញកិច្ចការមួយក្នុងចំណោមកិច្ចការដូចជា ការប្រើពូថៅនិងប៉ែលដើម្បីជីកដីឥដ្ឋពីពំនូកដី ការលើកដីឥដ្ឋដាក់ចូលក្នុងម៉ាស៊ីនផលិតឥដ្ឋតូច/ធំ ដឹកឥដ្ឋនឹងរទេះឈើតូចឬត្រាក់ទ័រ ហាលឥដ្ឋក្រោមកម្តៅថ្ងៃ ដឹកឥដ្ឋដែលហាលរួចយកទៅដាក់ក្នុងឡឥដ្ឋ ពុសអុសសម្រាប់ដុតក្នុងឡ បិទមាត់ឡជាមួយនឹងដីឥដ្ឋ និងជញ្ជូនឥដ្ឋចេញពីឡទៅដាក់ក្នុងរថយន្តជាដើម។

ការងារនៅក្នុងសិប្បកម្មផលិតឥដ្ឋ ពិតជាត្រូវការកម្លាំងកាយខ្លាំងណាស់ ជាពិសេសចំពោះកុមារ។ កុមារម្នាក់ក្នុងចំណោមកុមារដែលបានផ្តល់ការសម្ភាស បាននិយាយថាគាត់ក្រោកពីគេងនៅម៉ោង៣ ព្រឹកជារៀងរាល់ថ្ងៃដើម្បីជីកដី។ គាត់ធ្វើបែបនេះដើម្បីឲ្យគាត់អាចបញ្ចប់កិច្ចការដែលត្រូវប្រើកម្លាំងកាយខ្លាំងនេះ មុនពេលថ្ងៃក្តៅខ្លាំង។ អំឡុងពេលនៃការចុះស្រាវជ្រាវបុគ្គលិកអង្គការលីកាដូ ក៏បានសង្កេតមើលកុមារដទៃទៀតដែលកំពុងធ្វើការ ហើយបានឃើញថាពួកគេមានការលូតលាស់សាច់ដុំខុសពីធម្មតា ជាពិសេសជុំវិញឆ្អឹងខ្នងរបស់ពួកគេដែលនេះ អាចបណ្តាលមកពីការធ្វើការដោយប្រើកម្លាំងកាយធ្ងន់ធ្ងរពេក។

កុមារ៥ នាក់ក្នុងចំណោមកុមារចំនួន៨ នាក់ដែលបានផ្តល់បទសម្ភាសជាលក្ខណៈបុគ្គល បាននិយាយថាពួកគេទទួលបានការសិក្សានៅសាលារៀន។ ពួកគេទៅរៀននៅពេលព្រឹកឬពេលរសៀល ហើយពួកគេជួយការងារឪពុកម្តាយក្រោយពេលបញ្ចប់ពីការសិក្សា។ កុមារទាំង៣នាក់ដែលមិនបានទៅសាលារៀន ធ្លាប់បានទៅរៀនកាលពីមុន ប៉ុន្តែក្រោយមកក៏បានបោះបង់ការសិក្សាទៅវិញ។ កុមារអាយុ១១ឆ្នាំម្នាក់ក្នុងចំណោមកុមារទាំងនោះបានចាប់ផ្តើមធ្វើការតាំងពីអាយុ៥ឆ្នាំ ហើយបានបោះបង់ការសិក្សានៅថ្នាក់ទី២។នៅពេលសួរថាហេតុអ្វីបានជាពួកគាត់ត្រូវធ្វើការ ពួកគាត់៣នាក់ បាននិយាយថាដោយសារឪពុកម្តាយរបស់ពួកគាត់ជំពាក់បំណុលគេ។ រីឯកុមារដទៃទៀតបានលើកឡើងអំពីភាពក្រីក្រនៅក្នុងគ្រួសារ ឬការអាណិតអាសូរចំពោះឪពុកម្តាយ ហើយពួកគាត់ចង់ជួយឪពុកម្តាយ។

**គ្រួសារនោះមានកូន៣នាក់ ប៉ុន្តែមានលទ្ធផលបញ្ជូនកូនឲ្យទៅសាលារៀនត្រឹមតែម្នាក់ប៉ុណ្ណោះ។ បងប្អូនពីរនាក់ទៀតដែលមិនបានទៅសាលារៀន បាននិយាយថាពួកគាត់ចង់ទៅរៀនជាមួយបង/ប្អូន ហើយចង់ចេះអាននិងសរសេរអក្សរ ប៉ុន្តែពួកគាត់មិនដែលបានទៅសាលារៀន នោះទេ។**

ក្រៅពីភាពចាំបាច់ ដែលកុមារទាំងនោះត្រូវធ្វើការដើម្បីបង្កើនប្រាក់ចំណូលរបស់ឪពុកម្តាយ ថ្លៃសិក្សានៅសាលារៀន ក៏ជាឧបសគ្គមួយសម្រាប់គ្រួសារជាច្រើនផងដែរ។ ជាគោលការណ៍សាលារដ្ឋគឺមិនតម្រូវឲ្យមានការបង់ប្រាក់នោះទេ ប៉ុន្តែវាជារឿងសាមញ្ញនៅទូទាំងប្រទេសកម្ពុជា ដែលគ្រូបង្រៀនតម្រូវឲ្យសិស្សបង់ប្រាក់ក្រៅផ្លូវការដើម្បីទទួលបានការសិក្សានៅសាលារៀន។ បុគ្គលិកអង្គការលីកាដូ បានជួបជាមួយគ្រួសារមួយដែលរស់នៅក្នុងសិប្បកម្មផលិតឥដ្ឋក្នុងឃុំព្រែកអញ្ចាញ។ ពួកគាត់បានរៀបរាប់ថា ថ្លៃសិក្សានៅសាលារដ្ឋដែលស្ថិតនៅក្បែរនោះគឺ៥០០រៀល[៦] (១២.៥ សេន ដុល្លារ) ក្នុងមួយថ្ងៃ ហើយថ្លៃសិក្សាក្រៅម៉ោងបន្ថែមជាមួយគ្រូដដែលលើមុខវិជ្ជា ដូចជាគណិតវិទ្យា និងអក្សរសាស្ត្រខ្មែរគឺ ៥០០រៀលក្នុង១ម៉ោង។ គ្រួសារនោះមានកូន៣ នាក់ប៉ុន្តែមានលទ្ធផលបញ្ជូនកូនឲ្យទៅសាលារៀនត្រឹមតែម្នាក់ប៉ុណ្ណោះ។ បងប្អូនពីរនាក់ទៀតដែលមិនបានទៅសាលារៀនបាននិយាយថា ពួកគាត់ចង់ទៅរៀនជាមួយបង/ប្អូន ហើយចង់ចេះអាននិងសរសេរអក្សរ ប៉ុន្តែពួកគាត់មិនដែលបានទៅសាលារៀននោះទេ។

៦ ប្រាក់រៀលរបស់កម្ពុជា

## ករណីសិក្សា - ពីង

ពីង មានអាយុ១០ឆ្នាំ។ នាងចាប់ផ្តើមធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋ នៅពេលនាងមានអាយុ៩ឆ្នាំ។ នាងជាអ្នកលើកឥដ្ឋដែលទើបផលិតរួចថ្មីៗទៅដាក់លើរថយន្តដើម្បីដឹកជញ្ជូនទៅចែកចាយតាមការដ្ឋានសាងសង់ជុំវិញរាជធានីភ្នំពេញ។ នាងទទួលបានប្រាក់កម្រៃ១រៀល (០.០២៥ សេន ដុល្លារ) សម្រាប់ការលើកដាក់ឥដ្ឋ១ដុំ។ រថយន្តនីមួយៗដឹកឥដ្ឋបានប្រមាណ១៥.០០០ឥដ្ឋ ហើយឥដ្ឋមួយដុំៗមានទម្ងន់ ប្រហែល ១ គីឡូក្រាម។ ជាធម្មតា ពីងលើកឥដ្ឋដាក់លើរថយន្តបានចំនួន១រថយន្ត (ទម្ងន់ ១៥ តោន) នៅពេលព្រឹកមុនពេលនាងទៅសាលារៀននាពេលរសៀល។ នៅពេលមមាញឹកខ្លាំងពីងមិនបានទៅសាលារៀននោះទេ ហើយត្រូវលើកដាក់ឥដ្ឋពេញមួយថ្ងៃ។ កាលពីមុន នាងលើកឥដ្ឋដាក់លើរថយន្តបានចំនួន៣រថយន្តក្នុង១ថ្ងៃ ដែលមានទម្ងន់សរុបប្រហែល៤៥តោន។ ពីងបាននិយាយថា នាងធ្វើការដើម្បីជួយដោះបំណុលដែលឪពុកម្តាយនាងជំពាក់ម្ចាស់សិប្បកម្ម។ ម្ចាស់សិប្បកម្មអះអាងថា គាត់មិនបានប្រើប្រាស់ពលកម្មកុមារនោះទេ ប៉ុន្តែគាត់អនុញ្ញាតឲ្យអ្នកដឹកជញ្ជូនឥដ្ឋ (អ្នកស៊ីឈ្នួលដឹកជញ្ជូនឯកជន) ប្រើប្រាស់ពលកម្មកុមារក្នុងសិប្បកម្មរបស់គាត់។ ឪពុកម្តាយរបស់ពីងជំពាក់ប្រាក់ម្ចាស់សិប្បកម្មប្រហែល ៣.០០០ដុល្លារ។ ពីងមានបងស្រី២នាក់និងប្អូនប្រុស២នាក់ ហើយនាងបានប្រាប់ថា ប្រសិនបើនាងមិនធ្វើការ នោះគ្រួសារនាងមិនមានម្ហូបអាហារដើម្បីទទួលទាននោះទេ។ ឪពុកម្តាយរបស់នាងមានការព្រួយបារម្ភចំពោះនាងជាខ្លាំងពីព្រោះ បន្ទាប់ពីធ្វើការបាន១ឆ្នាំរួចមក នាងចាប់ផ្តើមឈឺខ្នង ឈឺដើមទ្រូង ពិបាកដកដង្ហើម និងគេងមិនលក់នៅពេលយប់ជាប្រចាំ។ ទោះបីជានាងខិតខំរៀនសូត្រយ៉ាងខ្លាំងដើម្បីទទួលបានចំណាត់ថ្នាក់ល្អ ក៏គ្រូបង្រៀនរបស់នាងមានការព្រួយបារម្ភចំពោះការសិក្សារបស់នាង ដោយសារតែចំណាត់ថ្នាក់របស់នាងមានការធ្លាក់ចុះពេលណាសិប្បកម្មមានភាពមមាញឹកខ្លាំង ហើយនាងមិនអាចមករៀនបាន។ ពីងក៏បានប្រាប់ថា នាងត្រូវបានស្គាល់ថាជាអ្នកលើកដាក់ឥដ្ឋពូកែម្នាក់ ហើយពេលខ្លះអ្នកបើកបររថយន្តដឹកឥដ្ឋមួយចំនួនទៅយកនាងពីក្បែរសាលារៀនមកសិប្បកម្មដែលនាងស្នាក់នៅ។



ក្មេងស្រីកំពុងប្រមូលឥដ្ឋដែលបានដុតរួចចេញពីឡ

## ដំណើរការនៃការផលិតឥដ្ឋ

ឥដ្ឋនៅកម្ពុជា ត្រូវបានផលិតឡើងដោយការលាយដីឥដ្ឋជាមួយទឹក និងដីធម្មតា រួចចាក់ពុម្ពឥដ្ឋនិងហាលថ្ងៃ មុនពេលដុតឥដ្ឋកម្ដៅ ក្នុងសីតុណ្ហភាពខ្ពស់កំផុតនៅក្នុងឡឥដ្ឋដែលដុតដោយអុស។ ជាទូទៅ ឡឥដ្ឋមានកម្ដៅចន្លោះពី៩០០ ទៅ១.២០០អង្សារសេ។

ដំណើរការនៃការផលិតឥដ្ឋ ត្រូវការកម្លាំងពលកម្មខ្លាំង។ នៅទសវត្សរ៍ចុងក្រោយនេះ សិប្បកម្មផលិតឥដ្ឋមួយចំនួនបានបង្កើនការប្រើប្រាស់គ្រឿងម៉ាស៊ីនប៉ុន្តែសូម្បីតែ ដំណើរការដោយប្រើប្រាស់គ្រឿងម៉ាស៊ីនច្រើន ក៏នៅតែអាស្រ័យលើកម្លាំងពលកម្មរបស់មនុស្សដែរ។ នៅក្នុងសិប្ប-កម្ម ដែលប្រើគ្រឿងម៉ាស៊ីនទំនើបៗ ដីឥដ្ឋ និងដីធម្មតា ត្រូវបានដាក់ចូលក្នុងម៉ាស៊ីនដោយគ្រឿងម៉ាស៊ីន ហើយលាយ និងចាក់ពុម្ពឥដ្ឋក្នុងពេលតែមួយ មុនពេលឥដ្ឋឆៅត្រូវបានកាត់ជាកំណាត់ដុំឥដ្ឋសម្រាប់ហាលថ្ងៃនិងដុតកម្ដៅ។

ឥដ្ឋ ត្រូវបានដុតកម្ដៅក្នុងសីតុណ្ហ-ភាពខ្ពស់ខ្លាំងរយៈពេលជាច្រើនថ្ងៃ ដោយប្រើប្រាស់កំណាត់ ឈើជាច្រើនដុំ។ សិប្ប-កម្មមួយចំនួនប្រើប្រាស់សំរាម និងកំទេចក្រណាត់ដើម្បីដុតជំនួសអុស។ ឡឥដ្ឋភាគច្រើន មានទំហំធំណាស់អាចឲ្យកម្មករបើកត្រាក់ទ័រចូលបាន។

បន្ទាប់ពីដុតកម្ដៅរួចមកឥដ្ឋត្រូវបានទុកឲ្យត្រជាក់។ បន្ទាប់មកឥដ្ឋអាចប្រើប្រាស់បាន ហើយត្រូវលើកដាក់រថយន្តដោយដៃ ដើម្បីយកទៅចែកចាយដល់ការ-ដ្ឋានសាងសង់ផ្សេងៗ។ ជាមធ្យម តម្លៃលក់រាយក្នុងឥដ្ឋមួយដុំចន្លោះពី២ សេន ទៅ៣សេនដុល្លារ ឬក៏ ៨០រៀល ទៅ ១២០រៀល។ តម្លៃពលកម្មសម្រាប់កម្មករជាមនុស្សពេញវ័យ ក្នុងឥដ្ឋមួយដុំទទួលបាន ០.០៥សេនដុល្លារ ឬ២រៀល។



ក្មេងៗធ្វើការនៅកន្លែងម៉ាស៊ីនកាត់ឥដ្ឋ

# សិប្បកម្មឡឥដ្ឋនិង ប៉ុស្តិ៍នគរបាលនៅក្នុង និងជុំវិញរាជធានីភ្នំពេញ

២.៥គីឡូម៉ែត្រ
ពីទីតាំងស្នូល

\#

ចំនួនសិប្បកម្ម ដែល
ស្ថិតនៅក្នុងទីតាំងមួយៗ

◆ ប៉ុស្តិ៍នគរបាលរដ្ឋបាល




រាជធានីភ្នំពេញ

0 ៥ គីឡូម៉ែត្រ





៦១
១០
ឡឥដ្ឋ
រការកោង
៧
ឡឥដ្ឋ
ព្រែកដំបង
៦A
៥
ឡឥដ្ឋ
ឫស្សីជ្រោយ
២០
ឡឥដ្ឋ
ព្រះប្រសប់
៣៩
ឡឥដ្ឋ
ព្រែកអញ្ចាញ
៨
២២
ឡឥដ្ឋ
បាក់ខែង
១០
ឡឥដ្ឋ
ស្វាយប៉ាក



គេហដ្ឋានរបស់ម្ចាស់សិប្បកម្មផលិតឥដ្ឋ

## ស្ថានភាពនៅក្នុងសិប្បកម្មផលិតឥដ្ឋ

សិប្បកម្មផលិតឥដ្ឋ ជាកន្លែងដែលមានបរិយាកាសការងារប្រកបដោយគ្រោះថ្នាក់ដោយសារតែឡឥដ្ឋក្តៅខ្លាំង ម៉ាស៊ីនដំណើរការលឿន គំនរឥដ្ឋមិនមានលំនឹង និងធូលីដែលអាចបង្កឲ្យមានគ្រោះថ្នាក់។ ជាទូទៅការងារជាមួយគ្រឿងម៉ាស៊ីនប្រឈមនឹងគ្រោះថ្នាក់ខ្លាំងណាស់ ប្រសិនបើកម្មករធ្វើការជាមួយផ្នែកខ្លះរបស់វាដូចជា ខ្សែពានម៉ូទ័រនិងមុខកំបិត។ បរិវេណសិប្បកម្មមានភាពរញ៉េរញ៉ៃពេញដោយគំនរអុស និងគំនរដីឥដ្ឋកម្ពស់រាប់សិបម៉ែត្រដែលមិនមានលំនឹង។ ភាគច្រើនកុមារជាអ្នកបើកបរគ្រឿងចក្រធុនធ្ងន់ក្នុងបរិវេណសិប្បកម្ម ដោយមានការឃ្លាំមើលតិចតួចឬមិនមានទាល់តែសោះ។

កម្មករដែលធ្វើការដើម្បីដោះបំណុល និងក្រុមគ្រួសាររបស់ពួកគាត់រស់នៅក្នុងបរិវេណសិប្បកម្មផលិតឥដ្ឋ។ កម្មករដែលបានផ្តល់ការសម្ភាសមួយចំនួន បានលើកឡើងថា ការផ្តល់កន្លែងស្នាក់នៅជាកត្តាទាក់ទាញមួយដែលនាំឲ្យពួកគាត់មកធ្វើការនៅសិប្បកម្មផលិតឥដ្ឋ ប៉ុន្តែកន្លែងស្នាក់នៅដែលផ្តល់ដោយម្ចាស់សិប្បកម្មនោះ គឺមិនមានអ្វីច្រើនទេ ហើយត្រូវបានសាងសង់ឡើងដោយឈើនិងបន្ទះដែកគ្មានគុណភាព ដែលត្រឹមតែអាចជ្រកបានតែប៉ុណ្ណោះ។ ស្ទើរតែគ្មានការបែងចែកឬគ្មានសោះតែម្តងរវាងកន្លែងធ្វើការនិងកន្លែងស្នាក់នៅរបស់កម្មករ ដែលធ្វើឲ្យពួកគាត់ប្រឈមនឹងគ្រោះថ្នាក់ ដោយសារគ្រឿងម៉ាស៊ីននិងស្ថានភាពបរិយាកាសជុំវិញដូចបានរៀបរាប់ខាងលើ។ កន្លែងស្នាក់នៅមានភាពតូចចង្អៀត ហើយគ្មានការថែទាំឲ្យបានត្រឹមត្រូវ ដោយសារគ្មានការបិទបាំងជាលក្ខណៈឯកជនរវាងសមាជិកនៅក្នុងគ្រួសារនិងកម្មករដទៃទៀត។ តំបន់សិប្បកម្មផលិតឥដ្ឋភាគច្រើ នដែលបានធ្វើការស្រាវ-ជ្រាវ គឺខ្វះអនាម័យ ដោយសារគ្មានបង្គន់និងទឹកស្អាតសម្រាប់ប្រើប្រាស់។ ផ្ទុយទៅវិញ ម្ចាស់សិប្បកម្មរស់នៅក្នុងវីឡាថ្មីទំនើបដែលអាចមើលមកឃើញសិប្បកម្មនោះ។

អំឡុងពេលចុះធ្វើការស្រាវជ្រាវ បុគ្គលិកអង្គការលីកាដូមិនត្រឹមតែឃើញកុមារធ្វើការ និងប្រើប្រាស់គ្រឿងម៉ាស៊ីនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឃើញកុមារលេងក្បែរឡឥដ្ឋ រួមទាំងគំនរដីឥដ្ឋដែលគ្មានលំនឹង គំនរឥដ្ឋដែលកំពុងហាលកម្តៅថ្ងៃ ម៉ាស៊ីនកាត់ឈើ និងម៉ាស៊ីនកិនដីទៀតផង។ នៅក្នុងសិប្បកម្មមួយនោះ កុមារអាយុក្រោម ២ឆ្នាំម្នាក់ ត្រូវបានឃើញថាកំពុងដេកក្នុងអង្រឹងដែលចងនៅចន្លោះឡឥដ្ឋនៅក្បែរកម្មករកំពុងដុតភ្លើងឡ។ កុមារអាយុក្រោម៥ ឆ្នាំម្នាក់ក៏ត្រូវបានឃើញនៅក្នុងកន្លែងបើកបរគ្រឿងចក្រសម្រាប់កាយដី ខណៈដែលសមាជិកគ្រួសារកំពុងកាប់ដីពីគំនរដីធំៗ ដែលស្ថិតនៅព័ទ្ធជុំវិញបរិវេណសិប្បកម្មនោះ។

## ការរងរបួស

ការប្រើប្រាស់គ្រឿងម៉ាស៊ីន នៅក្នុងសិប្បកម្មផលិតឥដ្ឋ និងស្ថានភាពដែលកុមារធ្វើការងាររស់នៅ និងលេងនៅក្នុងបរិវេណសិប្បកម្មមានន័យថា ហានិភ័យនៃការទទួលរងគ្រោះថ្នាក់គឺមានខ្ពស់។ ការធ្វើការច្រើនម៉ោងជាមួយម៉ាស៊ីនដែលងាយបង្កគ្រោះថ្នាក់ និងលក្ខណៈការងារដែលប្រើប្រាស់កម្លាំងពលកម្មខ្លាំង ក៏អាចបង្កឲ្យមនុស្សពេញវ័យដែលធ្វើការជាមួយម៉ាស៊ីននោះប្រឈមនឹងហា-

និភ័យផងដែរ នៅពេលណាពួកគាត់ធ្វេសប្រហែសតែបន្តិចអាចនឹងធ្វើឲ្យមានផលលំបាកធ្ងន់ធ្ងរ។ គ្រោះថ្នាក់ដែលកើតមានជាញឹកញាប់បំផុតគឺអាចជាការដាច់ដៃត្រឹមលើកែងដៃ។

ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ អង្គការលីកាដូបានធ្វើការស៊ើបអង្កេតលើករណីចំនួន៣ ដែលពាក់ព័ន្ធនឹងករណីកុមារដាច់ដៃដោយសារម៉ាស៊ីនផលិតឥដ្ឋ។ ករណីទី១គឺពាក់ព័ន្ធនឹងកុមារម្នាក់ អាយុ៧ឆ្នាំដែលលេងនៅក្បែរម្តាយរបស់គាត់ ខណៈពេលម្តាយគាត់កំពុងធ្វើការជាមួយម៉ាស៊ីនផលិតឥដ្ឋដែលគ្មានគំរប។ ករណីទី២ពាក់ព័ន្ធនឹងក្មេងប្រុសម្នាក់អាយុ៩ ឆ្នាំដែលកំពុងធ្វើការដាក់ដីចូលក្នុងម៉ាស៊ីន។ ករណីទី៣គឺកើតមានចំពោះកុមារអាយុ១៤ឆ្នាំម្នាក់ ដែលកំពុងធ្វើការដាក់ដីចូលក្នុងម៉ាស៊ីនផលិតឥដ្ឋដែរ។ កុមារាអាយុ៩ឆ្នាំបានបាត់បង់អាយុជីវិតដោយសារតែរបួសរបស់គាត់។

**ក្នុងរយៈពេល២ឆ្នាំចុងក្រោយនេះ អង្គការលីកាដូបានធ្វើការស៊ើបអង្កេតលើករណីចំនួន៣ ដែលពាក់ព័ន្ធនឹងករណីកុមារដាច់ដៃដោយសារម៉ាស៊ីនផលិតឥដ្ឋ... កុមារម្នាក់បានបាត់បង់ជីវិតដោយសារការរងរបួស។**

ស្ត្រីម្នាក់ក្នុងចំណោមមនុស្សពេញវ័យ ដែលបានផ្តល់ការសម្ភាសជាលក្ខណៈបុគ្គល បានបាត់បង់ដៃស្តាំរបស់គាត់កាលពី១០ឆ្នាំមុន។ ស្ត្រីម្នាក់ទៀតបានរៀបរាប់អំពីរឿងហេតុដែលនាំឲ្យស្វាមីរបស់គាត់ពិការភ្នែកបន្ទាប់ពីផ្កាភ្លើងបានធ្លាក់ចូលក្នុងភ្នែកស្វាមីរបស់គាត់ ហើយភ្នែកស្វាមីរបស់គាត់ក៏មានការឆ្លងមេរោគ។ បុរសម្នាក់បានទទួលរងការបាក់ដៃ ហើយបុរសម្នាក់ទៀតបានឲ្យដឹងថាកូនប្រុសគាត់ដាច់ម្រាមដៃមួយ បន្ទាប់ពីរទេះដែលដឹកឥដ្ឋពេញបានធ្លាក់លើកូនគាត់។ ក្នុងករណីទាំងបួននេះ ម្ចាស់សិប្បកម្មផលិតឥដ្ឋ បានរ៉ាប់រងចំពោះការចំណាយព្យាបាលជាបន្ទាន់ ប៉ុន្តែក្នុងនោះមានពីរករណីដែលថ្លៃចំណាយព្យាបាលត្រូវបានបូកបញ្ចូលបន្ថែម ទៅក្នុងប្រាក់បំណុលដែលកម្មករបានជំពាក់ម្ចាស់សិប្បកម្មកន្លងមក។ គ្មានករណីណាមួយដែលម្ចាស់សិប្បកម្មបានរ៉ាប់រងចំពោះការចំណាយព្យាបាលរយៈពេលយូរ ឬផ្តល់ថ្នាំបំបាត់ការឈឺចាប់នោះទេ។

ចំនួនទិន្នន័យគ្រោះថ្នាក់ និងរងរបួសនៅសិប្បកម្មផលិតឥដ្ឋមិនត្រូវបានដឹងឮនោះទេពីព្រោះ មិនមានការកត់ត្រាសរុប។ ការរងរបួសដែលបានរៀបរាប់ខាងលើគឺគ្រាន់តែជាករណី ដែលបានរាយការណ៍មកអង្គការលីកាដូនាពេលថ្មីៗនេះ និងជាព័ត៌មានដែលទទួលបានពីការសម្ភាសមួយចំនួនកន្លងមកតែប៉ុណ្ណោះ។ នេះអាចបង្ហាញថាការរងរបួសអាចកើតឡើងជាញឹកញាប់។



រណាកាត់ឈើសំរាប់យកទៅដុតក្នុងឡឥដ្ឋ



ម្ដាយ និងកូនប្រុសលើកឥដ្ឋដាក់ក្នុងឡានដើម្បីដឹកយកមកភ្នំពេញ

## ករណីសិក្សា - ស្រីនិច

ស្រីនិចអាយុ៥០ឆ្នាំ។ គាត់បានចាប់ផ្ដើមធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋរយៈពេល១៥ឆ្នាំមកហើយដោយសារតែគាត់ជំពាក់ប្រាក់ម្ចាស់បំណុលជាច្រើន ហើយបានលក់ដីស្រែអស់។ គាត់ត្រូវការប្រាក់សម្រាប់សម្រាលកូនប្រុសពៅរបស់គាត់ ហេតុនេះហើយទើបបានជាគាត់សុំខ្ចីប្រាក់ពីម្ចាស់សិប្បកម្ម ហើយក៏ធ្វើការនៅទីនោះតែម្ដង។ ការងារចំបងរបស់គាត់គឺលើកឥដ្ឋដាក់ឡាន លើកដីឥដ្ឋ ឬជុំឥដ្ឋដាក់រទេះ និងហាលឥដ្ឋក្រោមកម្ដៅថ្ងៃ។ គាត់រកបានប្រាក់ឈ្នួលប្រមាណពី៥.០០០រៀល ទៅ១០.០០០រៀល (១.២៥ - ២.៥ ដុល្លារ) ក្នុងមួយថ្ងៃ។ មានថ្ងៃខ្លះ គាត់មិនអាចរកប្រាក់បានទាល់តែសោះក៏មានដែរ។ វាអាស្រ័យថាតើមានរថយន្តមកដឹកឥដ្ឋឬអត់។ ប្រាក់ចំណូលរបស់គាត់គឺមិនគ្រប់គ្រាន់សម្រាប់ការចំណាយលើម្ហូបអាហារ អង្ករ និងសម្ភារៈដែលកូនគាត់ត្រូវការដើម្បីទៅសាលារៀននោះទេ។ ការចំណាយប្រចាំថ្ងៃរបស់គ្រួសារគាត់គឺប្រហែល២០.០០០រៀល (៥ ដុល្លារ)។ ប្រាក់បំណុលបច្ចុប្បន្នដែលគាត់ជំពាក់ម្ចាស់សិប្បកម្មមានចំនួន៦.០០០.០០០រៀល (១.៥០០ ដុល្លារ) ដែលមូលហេតុចម្បងគឺដោយសារតែការឈឺស្កាត់នៅក្នុងគ្រួសារ។ នៅពេលមាននរណាម្នាក់ក្នុងគ្រួសារមានជំងឺ ម្ចាស់សិប្បកម្មតែងតែផ្ដល់ប្រាក់ឲ្យខ្ចី ហើយកត់ចូលក្នុងបញ្ជីបំណុល។ ភ្នែករបស់ស្វាមីគាត់បានពិការដោយសារផ្កាភ្លើងបានធ្លាក់ចូលក្នុងភ្នែកអំឡុងពេលដែលគាត់កំពុងធ្វើការ។ ម្ចាស់សិប្បកម្មបានជួយដឹកស្វាមីរបស់គាត់ទៅកាន់មន្ទីរពេទ្យនៅខេត្តកំពង់ចាម ហើយបន្ទាប់មកទៀតបានដឹកមកភ្នំពេញ។ គ្រួសារគាត់ចំណាយប្រាក់ប្រមាណ១.០០០.០០០រៀល (២៥០ ដុល្លារ) សម្រាប់ការចំណាយថ្លៃព្យាបាលនោះ។ ម្ចាស់សិប្បកម្មបានឧបត្ថម្ភប្រាក់៥០ដុល្លារសម្រាប់ការព្យាបាលនោះ។ ក្រោយពីទទួលបានការព្យាបាលរួចហើយ ស្វាមីគាត់ចូលទៅធ្វើការវិញ ប៉ុន្តែភ្នែករបស់ស្វាមីគាត់មានការឆ្លងមេរោគ ហើយបានតម្រូវឲ្យខ្វេះគ្រាប់ភ្នែកនោះចេញតែម្ដង។ ស្វាមីគាត់បានឈប់ធ្វើការ។ ស្រីនិចមានក្ដីស្រមៃចង់មានចំការមួយ ហើយឲ្យកូនៗរបស់គាត់ថែទាំវា។ ប៉ុន្តែគាត់បានលើកឡើងថាដោយសារតែគាត់ក្រនិងជំពាក់ប្រាក់គេច្រើន ដូចនេះកូនៗរបស់គាត់ក៏នឹងក្រដែរ។ កូនៗរបស់គាត់នឹងមិនអាចចាកចេញពីសិប្បកម្មនោះបានទេនិងប្រហែលជាត្រូវធំលូតលាស់ដើម្បីធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋនោះតែម្ដង។

## ច្បាប់ស្ដីពីការជួញដូរ

ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ[៧] ("ហៅកាត់ថា ច្បាប់ស្ដីពី ការជួញដូរ) មានចែងយ៉ាងច្បាស់ អំពីការផ្ដន្ទាទោសចំពោះការប្រើប្រាស់ពលកម្មកុមារ។ មាត្រា១២ មានចែងពីបទល្មើសទាក់ទងនឹង "ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច"។ "ការជ្រើសរើសដោយមិនស្របច្បាប់" មានន័យថា ការបញ្ចុះបញ្ចូល ការជួល ឬការឲ្យបុគ្គលណាមួយបម្រើការ ក្រោមទម្រង់នៃការកេងប្រវ័ញ្ចតាមមធ្យោបាយបោកបញ្ឆោត បំពានអំណាច ការបង្ខាំងខ្លួន ការប្រើប្រាស់កម្លាំង ការគំរាមកំហែង ឬមធ្យោបាយបង្ខិតបង្ខំជាដើម។ "ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត"ត្រូវបានចែងក្នុងមាត្រា ១០ រួមមានទាំងការបញ្ចាំខ្លួនដោះបំណុលផងដែរ។ ការផ្ដន្ទាទោស ចំពោះការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចគឺជាប់ពន្ធនាគារចន្លោះពី៧ ឆ្នាំទៅ១ ៥ ឆ្នាំ ឬ ១៥ឆ្នាំទៅ២០ឆ្នាំ ប្រសិនបើជនរងគ្រោះមានអាយុក្រោម១៨ឆ្នាំ។ ការពឹងផ្អែកលើម្ចាស់សិប្បកម្មរបស់កម្មករដែលធ្វើការដើម្បីដោះបំណុល និងការមិនមានអំណាចក្នុងការតវ៉ា គួបផ្សំជាមួយនឹងការគំរាមកំហែងថាពួកគាត់អាចនឹងត្រូវចាប់ខ្លួន ប្រសិនបើពួកគាត់ប៉ុនប៉ងចាកចេញពីសិប្បកម្មដោយមិនទូទាត់សងប្រាក់បំណុល ទាំងអស់នេះហាក់ដូចជា ធ្វើឲ្យការបញ្ចាំខ្លួនដោះបំណុលនៅសិប្បកម្មផលិតឥដ្ឋស្ថិតក្រោមវិសាលភាពនៃ "ការជ្រើសរើសដោយមិនស្របច្បាប់"។

ការអនុវត្តការបញ្ចាំខ្លួនដោះបំណុលនៅក្នុងសិប្ប-កម្មផលិតឥដ្ឋ ប្រហែលជាស្ថិតក្រោមវិសាលភាពនៃមាត្រាផ្សេងទៀតនៃច្បាប់ស្ដីពីការជួញដូរផងដែរ ជាពិសេសមាត្រា ទាក់ទងនឹងការនាំយកចេញដោយមិនស្របច្បាប់ដែលមានន័យថា "ការនាំយកមនុស្សម្នាក់ពីទីកន្លែងដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃទៀត ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬ របស់តតិយជនតាមមធ្យោបាយបង្ខិតបង្ខំ គំរាមកំហែង បោកបញ្ឆោត បំពានអំណាច ឬលួងលោម"។ នៅពេលការនាំយកចេញដោយមិនស្របច្បាប់ត្រូវបានធ្វើឡើង ក្នុងគោលបំណងកេង-ប្រវ័ញ្ច រួមទាំងការបញ្ចាំខ្លួនដោះបំណុល ការផ្ដន្ទាទោស គឺដាក់ពន្ធនាគាររយៈពេលចន្លោះពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ ឬពី ១៥ឆ្នាំ ទៅ២០ឆ្នាំ ប្រសិនបើជនរងគ្រោះមានអាយុក្រោម ១៨ឆ្នាំ។ ច្បាប់ស្ដីពីការជួញដូរមិនមានចែងនូវលក្ខខណ្ឌដែលតម្រូវឲ្យធ្វើការឆ្លងដែន[៨] ឬកំណត់ចម្ងាយអប្បបរិមាជាក់លាក់ណាមួយ ដើម្បីចាត់ជាការនាំយកចេញដោយមិនស្របច្បាប់នោះទេ ដូច្នេះមានន័យថា ការនាំយកមនុស្សម្នាក់ចេញពីភូមិកំណើត ទៅកាន់សិប្បកម្មផលិតឥដ្ឋ គួរតែគ្រប់គ្រាន់ក្នុងការចាត់ជាការនាំយកចេញដោយមិនស្របច្បាប់។ នេះជាករណីដែលកើតមានចំពោះសិប្ប-កម្មផលិតឥដ្ឋទាំងអស់ដែលអង្គការលីកាដូបានដឹងកន្លងមក។ ការផ្ដល់ប្រាក់កម្ចីដោយមិនគិតការប្រាក់និងការផ្ដល់កន្លែងស្នាក់នៅឲ្យស្ទើរគ្រប់កម្មករទាំងអស់អាចត្រូវចាត់ជាការលួងលោម។ នៅពេលការលួងលោមត្រូវបានធ្វើឡើង ម្ចាស់សិប្បកម្មមិនអាចសំអាងលើហេតុផលថា កម្មករទាំងនោះ ជាអ្នកសម្រេចចិត្តទៅធ្វើការនៅសិប្បកម្មដោយខ្លួនឯងនោះទេ ហើយមិនអាចប្រើប្រាស់ហេតុផលនេះដើម្បីធ្វើការការពារខ្លួនបានឡើយ។[៩]

ច្បាប់ស្ដីពីការជួញដូរ ក៏មានចែងពីការផ្ដន្ទាទោសចំពោះអំពីជួញដូរមនុស្សផងដែរ។ អំពើជួញដូរមនុស្សមានន័យថា ការផ្ទេរនូវការគ្រប់គ្រងលើបុគ្គលណាម្នាក់ដោយដោះដូរជាមួយនឹងវត្ថុមានតម្លៃអ្វីមួយ[១០] ហើយអំពើនេះអាចត្រូវផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេលចាប់ពី២ ឆ្នាំទៅ៥ឆ្នាំ[១១]។ ប្រសិនបើគោលបំណងនៃការធ្វើអាជីវកម្មនោះដើម្បីកេងប្រវ័ញ្ចរួមទាំងការបញ្ចាំខ្លួនដោះបំណុល ការផ្ដន្ទាទោសគឺដាក់ពន្ធនាគាររយៈពេលចាប់ពី៧ឆ្នាំទៅ១៥ឆ្នាំ ឬ ១៥ឆ្នាំទៅ២០ឆ្នាំ ប្រសិនបើជនរងគ្រោះមានអាយុក្រោម ១៨ឆ្នាំ[១២]។ ក្នុងអំឡុងពេលនៃការស្រាវជ្រាវ អង្គការលីកាដូមិនបានជួបប្រទះនូវករណីជួញដូរកម្មករ ដែលធ្វើការដោះបំណុលរវាងម្ចាស់សិប្បកម្មផ្ទាល់នោះទេ។ ទោះជាយ៉ាងណា បទល្មើសនេះប្រហែលអាចអនុវត្តចំពោះករណី ដែលគ្រួសារកម្មករ ត្រូវបាននាំយកចេញពីសិប្បកម្មផលិតឥដ្ឋមួយទៅសិប្បកម្មផលិតឥដ្ឋមួយទៀត ដើម្បីជាមធ្យោបាយក្នុងការបង្កើនការខ្ចីប្រាក់។ ប្រាក់កម្ចីដែលទទួលបានពីម្ចាស់សិប្បកម្មថ្មី ត្រូវបានប្រើប្រាស់សម្រាប់យកទៅទូទាត់

[៧] ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ច្បាប់នេះអនុវត្តតាមពិធីសារដើម្បីទប់ស្កាត់ បង្ក្រាប និងផ្ដន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ឆ្នាំ២០០០ អង្គការសហប្រជាជាតិ។
[៨] ប្រសិនបើអំពើរួមផ្សំណាមួយនៃបទល្មើសជួញដូរប្រព្រឹត្តឡើងនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា នេះគ្រប់គ្រាន់ក្នុងការអនុវត្តច្បាប់ស្ដីពីការជួញដូរ តាមមាត្រា ២។
[៩] ច្បាប់ស្ដីពីការជួញដូរ មាត្រា ៨ និង ១០ សូមអានជាមួយគ្នា។
[១០] ច្បាប់ស្ដីពីការជួញដូរ មាត្រា ១៣
[១១] ច្បាប់ស្ដីពីការជួញដូរ មាត្រា ១៤
[១២] ច្បាប់ស្ដីពីការជួញដូរ មាត្រា ១៥



ក្មេងប្រុសចូកដីដាក់ចូលក្នុងម៉ាស៊ីនលាយដីឥដ្ឋ

សងម្ចាស់សិប្បកម្មចាស់ ដើម្បីរួចខ្លួនពីការគ្រប់គ្រងនៃម្ចាស់សិប្បកម្មចាស់ ប៉ុន្តែបង្កើតកាតព្វកិច្ចនិងទំនាក់ទំនងនៃការគ្រប់គ្រងដោយម្ចាស់សិប្បកម្មថ្មី។

## ច្បាប់ស្តីពីការងារ

ច្បាប់ស្តីពីការងាររបស់កម្ពុជាមានចែងនូវបទបញ្ញត្តិស្តីពីពលកម្មកុមារ ក្នុងគោលបំណងការពារកុមារពីការកេងប្រវ័ញ្ច និងការងារប្រកបដោយគ្រោះថ្នាក់ ដូចជាការងារនៅតាមសិប្បកម្មផលិតឥដ្ឋជាដើម។ យោងតាមមាត្រា១៧៧ កម្រិតអាយុអប្បបរមាដែលអាចធ្វើការងារក្នុងស្ថានភាពគ្រោះថ្នាក់ដល់សុខភាព និងសុវត្ថិភាព គឺអាយុ១៨ឆ្នាំ។[១៣]

ប្រទេសកម្ពុជា ក៏មានកាតព្វកិច្ចអនុវត្តតាមច្បាប់អន្តរជាតិ ដែលមិនអនុញ្ញាតឲ្យមានពលកម្មកុមារនិងការបញ្ចាំខ្លួនដោះបំណុល។ ក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ១៨២ របស់អង្គការពលកម្មអន្តរជាតិ ដែលអំពាវនាវឲ្យមានការហាមឃាត់ និងលុបបំបាត់រាល់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារជាបន្ទាន់[១៤]។ អនុសញ្ញានេះក៏បានចាត់ទុកការបញ្ចាំខ្លួនដោះបំណុល ជាទម្រង់មួយនៃទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារផងដែរ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយអង្គការពលកម្មអន្តរជាតិ ដើម្បីផ្តួចផ្តើមនូវ " ផែនការសកម្មភាពថ្នាក់ជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ" ក្នុងឆ្នាំ២០០៥។ ផែនការនេះមានទិសដៅកាត់បន្ថយអត្រានៃពលកម្មកុមារ ក្នុងចំណោមកុមារដែលមានអាយុចាប់ពី ៥ឆ្នាំ ទៅ ១៧ឆ្នាំ មកត្រឹម ៨ភាគរយ ត្រឹមឆ្នាំ២០១៥ និងបញ្ចប់ទាំងស្រុងនូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារត្រឹមឆ្នាំ២០១៦[១៥]។ ក្នុងឆ្នាំ២០០៧ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីប្រកាសលេខ៣០៩[១៦] ស្តីពីលក្ខខណ្ឌការងារនិងការរស់នៅក្នុងសិប្បកម្មផលិតឥដ្ឋ។ ប្រកាសនេះ មានចែងនូវលក្ខខណ្ឌទាក់ទងនឹងសម្លៀកបំពាក់ការពារ ការផ្តល់នូវសម្ភារៈបរិក្ខារសម្រាប់អនាម័យហើយក៏ធ្វើការហាមឃាត់យ៉ាងច្បាស់មិនឲ្យកុមារអាយុក្រោម ១៥ឆ្នាំ ធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋ ទោះបីជាកុមារនោះមានបំណងចង់ជួយឪពុកម្តាយក៏ដោយ[១៧]។ យោងតាមច្បាប់ស្តីពីការងារ អធិការកិច្ចការងារមានកាតព្វកិច្ចចុះត្រួតពិនិត្យគ្រប់គ្រឹះស្ថានការងារទាំងអស់ដើម្បីធានានូវការអនុវត្តបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ និងប្រកាសដែលពាក់ព័ន្ធ ហើយទាមទារឲ្យចាត់វិធានការចំពោះនយោជកណាដែលល្មើសនឹងបទបញ្ញត្តិទាំងនោះ[១៨]។ ការពិន័យជា

---

[១៣] ច្បាប់ស្តីពីការងារ មាត្រា ១៧៧

[១៤] អនុសញ្ញាស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ឆ្នាំ១៩៩៩ អង្គការពលកម្មអន្តរជាតិ http://www.ilo.org/dyn/normlex/en/f?p=NORMLEXPUB:12100:0::NO::P12100_INSTRUMENT_ID:312327.

[១៥] អង្គការពលកម្មអន្តរជាតិ ផែនការសកម្មភាព CAMFEBA ស្តីពីការលុបបំបាត់ពលកម្មកុមារ (WF) (CAMFEBA - PAECL) នៅកម្ពុជា (២០១២ - ២០១៦)ខែសីហា ឆ្នាំ២០១២ ទំព័រ ៥-៦។http://www.ilo.org/dyn/natlex/natlex_browse.details?p_lang=en&p_country=KHM&p_classification=04&p_origin=COUNTRY&p_sortby=SORTBY_COUNTRY.

[១៦] ប្រកាសជាប្រភេទមួយនៃច្បាប់បំពេញបន្ថែម

[១៧] អង្គការពលកម្មអន្តរជាតិ អង្គការ Winrock និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្រងប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មាត្រា ៦។

[១៨] ច្បាប់ស្តីពីការងារ មាត្រា២៣៣

ប្រាក់ត្រូវអនុវត្តនៅពេលនិយោជកមិនអនុវត្តតាមច្បាប់។ ការដាក់ទណ្ឌកម្ម ចំពោះការរំលោភបទបញ្ញត្តិពាក់ព័ន្ធនឹងពលកម្មកុមារ គឺការពិន័យជាប្រាក់ដែលមានតម្លៃស្មើនឹងតម្លៃពលកម្មគោលប្រចាំថ្ងៃចាប់ពី៣១ថ្ងៃទៅ៦០ថ្ងៃ។

## និទ្ទណ្ឌភាព

ការរៀបរាប់ខាងលើទាក់ទងនឹងច្បាប់ស្តីពីការហាមឃាត់និងការផ្តន្ទាទោសចំពោះការប្រើ ប្រាស់ការបញ្ចាំខ្លួនដោះបំណុល ពលកម្មកុមារ និងការអនុវត្តដែលពាក់ព័ន្ធផ្សេងទៀតគឺមិនទាន់អស់នៅ ឡើយទេ។ បទបញ្ញត្តិជាច្រើនទៀតក៏មានចែងពីបញ្ហាទាំងនេះដែរដូចជា ក្រមព្រហ្មទណ្ឌ[19] ច្បាប់ស្តីពីការងារ[20] ច្បាប់អន្តរជាតិ[21] ច្បាប់បន្ថែម[22] និងសូម្បីតែរដ្ឋធម្មនុញ្ញក៏មានដែរ[23]។ យោងតាមការពិភាក្សាជាមួយចៅសង្កាត់ ឬមេឃុំនិងមន្ត្រីនគរបាលនៅក្នុងតំបន់សិប្បកម្មផលិតឥដ្ឋមួយចំនួន បានបង្ហាញថាទាំងអាជ្ញាធររដ្ឋបាល និងអាជ្ញាធរអនុវត្តច្បាប់ បានដឹងច្បាស់អំពីការអនុវត្តដែលកើតមានក្នុងសិប្បកម្មផលិតឥដ្ឋទាំងនោះរួមទាំងការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ។ ប៉ុន្តែអាជ្ញាធរទាំងពីរផ្នែកនេះ ជារឿយៗតែងតែប្រងើយកន្តើយក្នុងការអនុវត្តច្បាប់ ចំពោះម្ចាស់សិប្បកម្មផលិតឥដ្ឋនៅកម្ពុជាហើយអង្គការលីកាដូមិនធ្លាប់បានដឹងអំពីការផ្តន្ទាទោស ឬសូម្បីតែពិន័យជាប្រាក់ចំពោះម្ចាស់សិប្បកម្មដែលមិនអនុវត្តតាមច្បាប់ទាំងនោះទេ។

សូម្បីតែករណីកម្មកររងរបួសធ្ងន់ធ្ងរ ម្ចាស់សិប្បកម្មនៅតែទទួលបាននិទ្ទណ្ឌភាព។ ក្នុងចំណោមករណីទាំងបីដែលអង្គការ លីកាដូ បានស៊ើបអង្កេតតាំងពីឆ្នាំ២០១៥ ឪពុកម្តាយរបស់កុមាររងគ្រោះមួយចំនួនបានព្យាយាមប្តឹងទៅមន្ត្រីនគរបាល ប៉ុន្តែមន្ត្រីនគរបាលបានបដិសេធបញ្ជូនសំណុំរឿងទាំងនោះទៅកាន់តុលាការ។ ក្នុងសំណុំរឿងមួយពាក់ព័ន្ធនឹងកុមារម្នាក់អាយុ១៤ឆ្នាំ មន្ត្រីនគរបាលបានប្រាប់ឪពុកម្តាយរបស់កុមារនោះថា គ្រោះថ្នាក់កើតឡើងដោយសារកំហុសរបស់ឪពុកម្តាយ ដែលឲ្យកូនធ្វើការ ហេតុដូចនេះ វាគ្មានប្រយោជន៍អ្វីដែលត្រូវប្តឹងទៅតុលាការនោះទេពីព្រោះពួកគាត់នឹងចាញ់ក្តី។ ម្ចាស់សិប្បកម្មក៏បានអះអាងថា នេះមិនមែនជាកំហុសរបស់គាត់ពីព្រោះគាត់មិនបានជួលកុមារឲ្យធ្វើការនោះទេ។ អង្គការលីកាដូបានពិភាក្សាជាមួយគ្រួសារនោះថា ពួកគាត់អាចដាក់ពាក្យប្តឹងបណ្តឹងស៊ីវិល និងបណ្តឹងព្រហ្មទណ្ឌទៅតុលាការ ប៉ុន្តែគ្រួសារនោះមានការស្ទាក់ស្ទើរ ពីព្រោះពួកគាត់បានប្រាប់ថា ម្ចាស់សិប្បកម្មមានសណ្តានចិត្តល្អចំពោះពួកគាត់។ គ្រួសារនោះ មិនទទួលបានសំណងអ្វីពីម្ចាស់សិប្បកម្មនោះទេ ប៉ុន្តែជាការដោះដូរម្ចាស់សិប្បកម្មបានលុបចោលប្រាក់បំណុលដែលពួកគាត់ជំពាក់ពាក់កណ្តាលពី៤.២០០ ដុល្លារមកត្រឹមតែ២.១០០ដុល្លារ។ គ្រួសារនោះមិនចង់បន្តរស់នៅក្នុងសិប្បកម្មផលិតឥដ្ឋនោះទៀតទេ បន្ទាប់ពីការព្រមព្រៀងនេះបានធ្វើឡើង ដូចនេះពួកគាត់បានខ្ចីប្រាក់ចំនួន២.១០០ដុល្លារពីម្ចាស់សិប្បកម្មផលិតឥដ្ឋមួយទៀតដើម្បីយកទៅសងម្ចាស់សិប្បកម្មចាស់ហើយពួកគាត់បានប្តូរទៅធ្វើការឲ្យម្ចាស់សិប្បកម្មថ្មីវិញ។ ពួកគាត់បន្តធ្វើការនៅសិប្បកម្មថ្មី ហើយកុមារាដែលធ្លាប់រងគ្រោះថ្នាក់នោះក៏ធ្វើការជាអ្នកបើកបរយានយន្តនៅសិប្បកម្មថ្មីដែរ។

ចំពោះករណីពាក់ព័ន្ធនឹងកុមារាម្នាក់អាយុ៧ឆ្នាំ មន្ត្រីនគរបាលបានបដិសេធមិនទទួលពាក្យបណ្តឹង ពីគ្រួសាររបស់កុមារានោះ។ មន្ត្រីនគរបាលនោះបានលើកឡើងថា គ្រោះថ្នាក់ដែលកើតឡើង ជាកំហុសរបស់ឪពុកម្តាយ ហើយដោយសារតែពេលជួបគ្រោះថ្នាក់ កុមារានោះកំពុងលេង មិនមែនធ្វើការទេ ហេតុនេះម្ចាស់សិប្បកម្មផលិតឥដ្ឋមិនមានទំនួលខុសត្រូវនោះទេ។ ដូចករណីខាងលើដែរ អង្គការ លីកាដូបានពិភាក្សាជាមួយគ្រួសារកុមាររងគ្រោះថា ពួកគាត់អាចដាក់ពាក្យបណ្តឹងផ្ទាល់ទៅតុលាការហើយចំពោះករណីនេះ គ្រួសារកុមាររងគ្រោះមិនមានការស្ទាក់ស្ទើរដោយសារការដឹងគុណចំពោះម្ចាស់សិប្បកម្ម ដូចករណីមុននោះទេ ពីព្រោះម្ចាស់សិប្បកម្មនេះធ្លាប់រំលោភបំពានទៅលើកម្មករ ហើយព្យួរប្រាក់ពលកម្មរបស់កម្មករជាញឹកញាប់។ទោះជាយ៉ាងណាម្តាយរបស់កុមាររងគ្រោះនៅជាប់ជំពាក់បំណុលម្ចាស់សិប្បកម្មនោះចំនួន៣.០០០

[19] មាត្រា ២៧៤ នៃក្រមព្រហ្មទណ្ឌកម្ពុជា ហាមឃាត់លក្ខខណ្ឌនៃការងារប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។

[20] មាត្រា ១៦ នៃច្បាប់ស្តីពីការងារហាមឃាត់ការងារដោះបំណុលរបស់កម្មករនិយោជិត។ មិនដូចបញ្ញត្តិនៅក្នុងច្បាប់ជួញដូរ ការល្មើសមាត្រានេះគ្រាន់តែមានការពិន័យនិយោជកជាប្រាក់ប៉ុណ្ណោះ។ មាត្រា ១៧៣ និង ១៧៦-១៧៩ នៃច្បាប់ស្តីពីការងារទាក់ទងនឹងកុមារ។

[21] ជាឧទាហរណ៍ មាត្រា ៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ទាក់ទងនឹងទាសភាព មាត្រា ៦ និង ៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ទាក់ទងនឹងសិទ្ធិធ្វើការងារ ជ្រើសរើសការងារ និងលក្ខខណ្ឌការងារអប្បបរមា មាត្រា ៣២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ទាក់ទងនឹងការកេងប្រវ័ញ្ច និងពលកម្មកុមារ អង្គការពលកម្មអន្តរជាតិ លេខ ២៩ (អនុសញ្ញាស្តីពីការងារដោយបង្ខំ) លំនាំដើមនៃអនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១០៥ (អនុសញ្ញាស្តីពីការលុបបំបាត់ការងារដោយបង្ខំ) មាត្រា ៣ នៃ អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ ១៣៨ (អនុសញ្ញាស្តីពីអាយុអប្បបរមា)។

[22] មាត្រា ១ និង ២ នៃប្រកាស ១០៦ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទារ (MOSALVY) ឆ្នាំ២០០៤ ហាមឃាត់កុមារមិនឲ្យធ្វើការនៅក្បែរឡឥដ្ឋ ប្រតិបត្តិ ឬ ថែទាំមធ្យោបាយដឹកជញ្ជូន និងគ្រឿងម៉ាស៊ីន ធ្វើការក្នុងសីតុណ្ហភាពក្តៅខ្លាំង ការលើកដាក់ធ្ងន់ដោយកុមារ មាត្រា ៣ និង ៤ នៃប្រកាស ៤៦៧ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៥ ហាមឃាត់ការជួលកម្មករនិយោជិតវ័យក្មេងធ្វើការងារបែបគ្រោះថ្នាក់ ប្រកាស ០០២ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឆ្នាំ២០០៨ ស្តីពីទម្រង់ការងារដែលអនុញ្ញាតសម្រាប់កុមារមានអាយុពី ១២ ទៅ ១៥ ឆ្នាំ។

[23] មាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញស្តីពីសិទ្ធិការងារ មាត្រា៣៨ ស្តីពីការការពារសេចក្តីថ្លៃថ្នូរ មាត្រា ៤៦ ស្តីពីការជួញដូរ មាត្រា ៤៨ ស្តីពីសិទ្ធិកុមារ និងពលកម្មកុមារ។ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិក៏អាចអនុវត្តបានតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញផងដែរ។

ដុល្លារ ដែលជាបំណុលជំពាក់ដោយកូនប្រសាររបស់គាត់ ប៉ុន្តែត្រូវធ្លាក់មកលើគាត់ដោយសារតែកូនប្រសារនោះបានលួចរត់ចេញពីសិប្បកម្មទៅហើយ។ មន្ត្រីនគរបាលបានប្រាប់គាត់ថា ប្រសិនបើគាត់ដាក់ពាក្យបណ្ដឹងទៅតុលាការ ម្ចាស់សិប្បកម្មនឹងដាក់ពាក្យបណ្ដឹងប្ដឹងគាត់ ដើម្បីឲ្យគាត់សងប្រាក់ជាបន្ទាន់ហើយគាត់នឹងត្រូវជាប់ពន្ធនាគារ។ ហេតុដូចនេះ គាត់មានការភ័យខ្លាចក្នុងការដាក់ពាក្យបណ្ដឹង ហើយក្រោយមកអង្គការលីកាដូ បានទទួលព័ត៌មានថា ក្រុមគ្រួសារគាត់ទាំងមូលបានរត់ចេញពីសិប្បកម្មទាំងកណ្ដាលយប់ ដើម្បីទៅរស់នៅជាមួយសាច់ញាតិនៅខេត្តផ្សេងទៀត។ នេះមានន័យថា គាត់មិនបានទទួលប្រាក់សំណង ហើយក៏មិនបានសងប្រាក់ម្ចាស់សិប្បកម្មនោះវិញដែរ។

ករណីចុងក្រោយពាក់ព័ន្ធនឹងកុមារដែលបានបាត់បង់ជីវិត ហើយសំណុំរឿងនេះកំពុងដំណើរការនៅឡើយ។ ដូចករណីខាងលើដែរ មន្ត្រីនគរបាលបានបដិសេធមិនចាត់វិធានការនោះទេ។ ដោយមានការអន្តរាគមពីអង្គការលីកាដូ ព្រះរាជអាជ្ញាបានបង្គាប់ឲ្យបញ្ជូនសំណុំរឿងនេះទៅតុលាការ។ គ្រោះថ្នាក់បានកើតឡើងកាលពីខែមេសា ឆ្នាំ២០១៦ ហើយព្រះរាជអាជ្ញាបង្គាប់ឲ្យបញ្ជូនសំណុំរឿងនៅខែមិថុនាឆ្នាំ២០១៦។ គិតត្រឹមពេលសរសេររបាយការណ៍នេះ មិនទាន់មានចំណាត់ការបន្ថែមទៀតនៅឡើយទេ។ បន្ទាប់ពីកុមារនោះទទួលមរណភាព ម្ចាស់សិប្បកម្មផលិតឥដ្ឋ បានផ្ដល់ប្រាក់ចំនួន ៥០០.០០០រៀល (១២៥ ដុល្លារ) ប៉ុន្តែកូនប្រុសរបស់ម្ចាស់សិប្បកម្មបានយកវិញចំនួន ២០០.០០០រៀល (៥០ ដុល្លារ) ដោយនិយាយថា ប្រាក់នេះសម្រាប់ថ្លៃថយន្តពេទ្យដែលដឹកកុមាររងគ្រោះទៅមន្ទីរពេទ្យ។

ករណីទាំង៣ខាងលើនេះ បានឆ្លុះបញ្ចាំងនូវកត្តាចម្បងៗដែលនាំឲ្យម្ចាស់សិប្បកម្មផលិតឥដ្ឋ គេចផុតពីការដាក់ទោស៖ ការភ័យខ្លាចនិងភក្ដីភាពដែលកម្មករមានចំពោះម្ចាស់សិប្បកម្មមានន័យថា ពួកគាត់មានការស្ទាក់ស្ទើរក្នុងការជម្រុញសំណុំរឿងរបស់ខ្លួនទៅក្នុងប្រព័ន្ធយុត្តិធម៌។ ការខ្វះខាតការគាំទ្រពីសំណាក់មន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋាន នឹងធ្វើឲ្យជនរងគ្រោះកាន់តែមានភាពស្ទាក់ស្ទើរថែមទៀត ដោយសារតែមើលទៅហាក់ដូចជាអាជ្ញាធរព្យាយាមការពារម្ចាស់សិប្បកម្មយ៉ាងខ្លាំងដើម្បី រួចផុតពីការផ្ដន្ទាទោស។

ភក្ដីភាពរបស់មន្ត្រីនគរបាល និងអាជ្ញាធរមូលដ្ឋានដែលមានចំពោះម្ចាស់សិប្បកម្មផលិតឥដ្ឋ មិនមែនជារឿងដែលគួរឲ្យភ្ញាក់ផ្អើលនោះទេនៅប្រទេសកម្ពុជា ដែលមានប្រព័ន្ធយុត្តិធម៌ពោរពេញដោយអំពើពុករលួយ[២៤]។ ចំពោះករណីដែលបានរៀបរាប់ខាងលើ បុគ្គលិកអង្គការលីកាដូមិនមានភ័ស្តុតាង ដើម្បីបញ្ជាក់ថាម្ចាស់សិប្បកម្មបានផ្ដល់ប្រាក់ទៅឲ្យមន្ត្រីនគរបាលឬអាជ្ញាធរមូលដ្ឋាននោះទេ ប៉ុន្តែបុគ្គលិកយើងបានធ្លាប់ឃើញ ម្ចាស់សិប្បកម្មបានផ្ដល់អំណោយដូចជា ស្រាបៀរ អាហារ និងប្រាក់ឧបត្ថម្ភទៅឲ្យមន្ត្រីនគរបាលនិងអាជ្ញាធរមូលដ្ឋាន នាពេលបុណ្យផ្សេងៗ ដូចជា បុណ្យចូលឆ្នាំខ្មែរ និងបុណ្យចូលឆ្នាំចិនជាដើម។ អំណោយទាំងនេះ ជាទម្រង់មួយនៃការឧបត្ថម្ភដើម្បីជួយរក្សានូវភក្ដីភាពពីសំណាក់អាជ្ញាធរ ចំពោះម្ចាស់សិប្បកម្មនៅពេលដែលម្ចាស់សិប្បកម្មត្រូវការជំនួយពីអាជ្ញាធរ។ ផ្ទុយទៅវិញ កម្មករសិប្បកម្មគ្មានលទ្ធភាពក្នុងការផ្ដល់អ្វីមួយដល់មន្ត្រីនគរបាលឬអាជ្ញាធរមូលដ្ឋាន ដើម្បីឲ្យអាជ្ញាធរជួយពួកគាត់នោះទេ។ ហេតុនេះទើបពួកគាត់គ្មានឱកាសទទួលបានសេវាល្អប្រសើរពីប្រព័ន្ធយុត្តិធម៌។

បើទោះជាមិនមានគ្រោះថ្នាក់កើតឡើងក្នុងសិប្បកម្មក៏ដោយ ការរំលោភធ្ងន់ធ្ងរលើច្បាប់ស្ដីពីការងារបានកើតមានឡើងជារៀងរាល់ថ្ងៃ ជាពិសេសការប្រើប្រាស់ពលកម្មកុមារនៅក្នុងសិប្បកម្មផលិតឥដ្ឋ ដែលនេះជារឿងខុសច្បាប់ ទោះបីជាម្ចាស់សិប្បកម្មមិនបានជួលកុមារឲ្យធ្វើការដោយផ្ទាល់ក៏ដោយ។ យោងតាមច្បាប់ស្ដីពីការងារ សិប្បកម្មផលិតឥដ្ឋ គួរតែទទួលបាននូវការចុះធ្វើអធិការកិច្ចជាប្រចាំ ដើម្បីធានាថាការរំលោភបំពានទាំងនេះត្រូវបានលុបបំបាត់។ ប៉ុន្តែមិនមានភស្តុតាងណាមួយដែលបង្ហាញថាការចុះធ្វើអធិការកិច្ចត្រូវបានធ្វើឡើងនោះទេ។ ក្នុងចំណោមមនុស្សពេញវ័យទាំង៨ នាក់ដែលបានផ្ដល់បទសម្ភាសជាលក្ខណៈបុគ្គលកាលពីឆ្នាំ២០១៥ ពួកគាត់៤នាក់បានលើកឡើងថា ពួកគាត់មិនដែលធ្លាប់បានឃើញនរណាម្នាក់ចុះមកធ្វើអធិការកិច្ចនៅក្នុងសិប្បកម្មនោះទេ។ ក្នុងចំណោមពួកគាត់៤នាក់ មានម្នាក់បានធ្វើការនៅសិប្បកម្មផលិតឥដ្ឋរយៈពេល១៧ឆ្នាំ និងម្នាក់ទៀតបានធ្វើការរយៈពេល១៥ឆ្នាំមកហើយ។ ពួកគាត់ម្នាក់បានប្រាប់ថា មន្ត្រីនគរបាលមូលដ្ឋាន និងមេភូមិ បានចុះមកម្ដងម្កាល។ ក្នុងចំណោមពួកគាត់៤នាក់ផ្សេងទៀត មានម្នាក់បានឲ្យដឹងថា ក្នុងរយៈពេល១៧ឆ្នាំកន្លងមក គាត់ធ្លាប់បានឃើញមន្ត្រីអធិការកិច្ចបានចុះមកម្ដង។ មន្ត្រីអធិការកិច្ចនោះបានប្រាប់ម្ចាស់សិប្បកម្ម ឲ្យសាងសង់បង្គន់អនាម័យសម្រាប់កម្មករ ហើយប្រាប់ឲ្យកម្មករបញ្ជូនកូនៗទៅសាលារៀន។ ពួកគាត់២នាក់ផ្សេងទៀតបាននិយាយថា គាត់មិនដែលធ្លាប់បានដឹងថា តើមានមន្ត្រីអធិការកិច្ចធ្លាប់ចុះមកនោះ

[២៤] វិទ្យាស្ថានសិទ្ធិមនុស្សគណៈមេធាវី រវាងយុត្តិធម៌ និងអំពើពុករលួយ៖ ឧបសគ្គចំពោះឯករាជ្យភាពនៃតុលាការកម្ពុជា ខែកញ្ញា ឆ្នាំ២០១៥។

ទេ។ មេឃុំម្នាក់ក្នុងចំណោមមេឃុំដែលបានផ្តល់បទសម្ភាសបានមានប្រសាសន៍ថា មន្ត្រីអធិការកិច្ចធ្លាប់ចុះមកម្តង បន្ទាប់ពីបានទទួលព័ត៌មានអំពីគ្រោះថ្នាក់ដែលបណ្តាលឲ្យកុមារាម្នាក់រងរបួស។ ប៉ុន្តែមន្ត្រីអធិការកិច្ចនោះបានចាកចេញទៅវិញ ដោយពុំមានចាត់វិធានការអ្វីនោះទេ ហើយក៏គ្មានអ្វីកើតឡើងបន្ទាប់ពីការចុះមកធ្វើអធិការកិច្ចនោះដែរ។



ក្មេងប្រុសកំពុងឈរធ្វើការពីលើម៉ាស៊ីនធ្វើពុម្ពឥដ្ឋ

# សេចក្តីសង្ខេប

របាយការណ៍នេះបង្ហាញអំពីការរីករាលដាលនៃការធ្វើការងារដើម្បីដោះបំណុលក្នុងសិប្បកម្មផលិតឥដ្ឋ នៅកម្ពុជា ហើយមធ្យោបាយដោះបំណុលនេះបានជម្រុញនិងគាំទ្រឲ្យមានពលកម្មកុមារ។ ការអនុវត្តទាំងពីរនេះមានការជាប់ពាក់ព័ន្ធគ្នាយ៉ាងខ្លាំងហើយកត្តាទាំងពីរនេះបានធ្វើឲ្យគ្រួសារជាច្រើនជំនាន់មិនអាចរួចចាកផុតពីភាពក្រីក្រ និងការជិះជាន់បានទេ។

កម្មករសិប្បកម្មផលិតឥដ្ឋទាំងអ ស់ចាប់ផ្តើមដោយភាពក្រីក្រ ដែលបណ្តាលមកពីកត្តាជាច្រើន ដូចជាការអត់ការងារធ្វើ គ្មានដី ការឈឺស្កាត់ ខ្វះជំនាញ និងខ្វះចំណេះដឹងគ្រប់គ្រាន់។ ហេតុនេះទើបពួកគាត់បានមកចាប់យកការងារនៅសិប្បកម្មផលិតឥដ្ឋ ដែលជាដំណោះស្រាយចំពោះបញ្ហាបន្ទាន់ដើម្បីផ្គត់ផ្គង់ជីវភាពរបស់ខ្លួន។ ម្ចាស់សិប្បកម្មកេងប្រវ័ញ្ចពីស្ថានភាពក្រីក្រ និងភាពអស់ជម្រើសរបស់កម្មករទាំងនោះ ហើយផ្តល់នូវលក្ខខណ្ឌការងារដែលមិនអាចធ្វើឲ្យពួកគាត់រួចចាកផុតពីភាពក្រីក្របាន។ ពួកគាត់ភាគច្រើន អាចរកប្រាក់ចំណូលបានត្រឹមតែសម្រាប់រស់នៅតែប៉ុណ្ណោះ ដោយសារតែបំណុលដែលពួកគាត់ជំពាក់ និងប្រាក់ឈ្នួលពលកម្មទាប។ ពួកគាត់មិនអាចធ្វើការសន្សំប្រាក់ទុកសម្រាប់ការចំណាយផ្សេងៗទៀតដូចជាពេលមានផ្ទៃពោះ ឬពេលមានជំងឺ ឬពេលរងរបួសដែលត្រូវការព្យាបាល ហើយនៅពេលដែលរឿងហេតុទាំងនេះកើតឡើង ពួកគាត់នឹងជំពាក់បំណុលកាន់តែច្រើនជាងមុនថែមទៀត។ ជាងនេះទៅទៀត ការងារនេះជម្រុញឲ្យពួកគាត់លើកទឹកចិត្តឲ្យកូនជួយធ្វើការ ដើម្បីបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ ដោយសារតែពួកគាត់ទទួលបានប្រាក់ឈ្នួលទៅតាមចំនួនផលិតផល ជំនួសឲ្យប្រាក់បៀវត្សរ៍ប្រចាំខែ។ ផលវិបាកមួយដែលបណ្តាលមកពីការអនុវត្តបែបនេះគឺថា កុមារមិនអាចទៅសាលារៀនបានឬបោះបង់ការសិក្សាទាំងខ្លួននៅក្មេងហើយកុមារភាគច្រើននៅតែមិនអាចយល់ដឹងសូម្បីតែជំនាញគិតលេខ និងអក្សរសាស្ត្រមូលដ្ឋាន។ ជាលទ្ធផល កុមារអាចធ្លាក់ចូលទៅក្នុងស្ថានភាពដូចឪពុកម្តាយរបស់គេដែរ ហើយអនាគតរបស់កុមារទាំងនោះ នឹងត្រូវទទួលរ៉ាប់រងសងបំណុលជំនួសឪពុកម្តាយ និងចុងបញ្ចប់បំណុលនោះអាចធ្លាក់រហូតដល់កូនៗរបស់កុមារទាំងនោះថែមទៀតផង។

បុគ្គលដែលទទួលបានអត្ថប្រយោជន៍ច្រើនបំផុត ពីការអនុវត្តបែបនេះ គឺម្ចាស់សិប្បកម្មផលិតឥដ្ឋដែលអាចជាអ្នកបន្តទទួលចំណេញពីកម្លាំងពលកម្មថោក និងស្តាប់បង្គាប់ ហើយអតិថិជនទិញឥដ្ឋ (ចាប់ពីបុគ្គលឯកជនសាងសង់ផ្ទះរបស់ខ្លួនរហូតដល់ក្រុមហ៊ុនជាតិ និងអន្តរជាតិដែលមាន គម្រោងសាងសង់សំណង់អគារធំៗ) អាចទិញឥដ្ឋក្នុងតម្លៃមួយទាបជាងយ៉ាងច្រើនពីតម្លៃកម្លាំងពលកម្មពិតដែលត្រូវការក្នុងការផលិតវា។

បើទោះជាភាពក្រីក្រ ដែលជាកត្តាជម្រុញឲ្យមនុស្សទៅធ្វើការនៅក្នុងសិប្បកម្មផលិតឥដ្ឋ ជាបញ្ហាស្មុគស្មាញពិបាកដោះស្រាយ ប៉ុន្តែបញ្ហានិទ្ទណ្ឌភាពដែលជម្រុញឲ្យម្ចាស់សិប្បកម្មទាំងនោះបន្តការកេងប្រវ័ញ្ច គឺមិនមានភាពស្មុគស្មាញពិបាកដោះស្រាយនោះទេ។ ទាំងការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ គឺជាការងារខុសច្បាប់ដែល ជាពិសេសមានការផ្តន្ទាទោសធ្ងន់ធ្ងរចំពោះការប្រើប្រាស់ការបញ្ចាំខ្លួនដោះបំណុល។ ទោះជាយ៉ាងណាបញ្ហាទាំងពីរនៅតែបន្តកើតមានជាទូទៅនៅចំពោះមុខនិងដឹងយ៉ាងច្បាស់ពីសំណាក់អាជ្ញាធរ ដែលអាជ្ញាធរគួរណាស់តែមានការទទួលខុសត្រូវខ្លះៗ ក្នុងការលុបបំបាត់បញ្ហាទាំងពីរដែរ។ អាជ្ញាធរនិងមន្ត្រីនគរបាលទាំងនោះ ត្រូវរាយការណ៍ និងចាត់វិធានការផ្លូវច្បាប់ចំពោះម្ចាស់សិប្ប-កម្មណា ដែលដំណើរការអាជីវកម្មរបស់ខ្លួនដោយពឹងផ្អែកលើការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារ។ អាជ្ញាធរមូលដ្ឋាន ត្រូវតែទទួលបានការគាំទ្រក្នុងការបំពេញកិច្ចការនេះពីសំណាក់តុលាការ រាជរដ្ឋាភិបាល និងអតិថិជនទិញឥដ្ឋ។ បើចំណាត់ការបែបនេះមិនត្រូវបានធ្វើឡើងនោះទេ ទម្រង់អាក្រក់នៃទាសភាពសម័យទំនើបនេះនឹងបន្តរីករាលដាលនៅក្នុងប្រទេសកម្ពុជា។



ឡដុតឥដ្ឋ

# អនុសាសន៍

## ►►► ចំពោះរាជរដ្ឋាភិបាលកម្ពុជា

សូមស្នើឲ្យរាជរដ្ឋាភិបាលចេញបទបញ្ជាជាបន្ទាន់ ដើម្បីលុបចោលបំណុលដែលមានទាំងអស់រវាងម្ចាស់សិប្បកម្មផលិតឥដ្ឋនិងកម្មករដែលធ្វើការដើម្បីដោះបំណុល ហើយសូមឲ្យប្រកាសផ្ដល់ការលើកលែងទោសដល់ម្ចាស់សិប្បកម្មណាដែលបានអនុវត្តតាមបទបញ្ជានេះចំពោះបទល្មើសដែលបានប្រព្រឹត្តកន្លងមក។ រាជរដ្ឋាភិបាលត្រូវធានាថាការប្រកាសនេះត្រូវបានផ្សព្វផ្សាយទៅដល់កម្មករ និងម្ចាស់សិប្បកម្មផលិតឥដ្ឋទាំងអស់។

រាជរដ្ឋាភិបាលគួរអនុវត្តច្បាប់ជាតិ និងអន្តរជាតិស្តីពីការបញ្ចាំខ្លួនដោះបំណុល ហើយជាពិសេសត្រូវធានាថាមានការផ្ដន្ទាទោសទៅតាមច្បាប់ស្តីពីការជួញដូរចំពោះម្ចាស់សិប្បកម្មផលិតឥដ្ឋណា ដែលបន្តឲ្យកម្មករធ្វើការដើម្បីដោះបំណុល។

រាជរដ្ឋាភិបាលត្រូវធានាថា នគរបាលមូលដ្ឋានមានធនធានគ្រប់គ្រាន់ដើម្បីធ្វើការស៊ើបអង្កេតឲ្យបានពេញលេញចំពោះបទល្មើសដែលប្រព្រឹត្តដោយម្ចាស់សិប្បកម្មផលិតឥដ្ឋ ហើយគួរដំឡើងប្រាក់បៀវត្សរ៍ជូនមន្ត្រីនគរបាល មន្ត្រីថ្នាក់ឃុំ និងមន្ត្រីអធិការកិច្ចការងារ ដើម្បីកាត់បន្ថយអំណាចរបស់ម្ចាស់សិប្បកម្មក្នុងការទិញទឹកចិត្តមន្ត្រីទាំងនោះ។

រាជរដ្ឋាភិបាលគួរផ្សព្វផ្សាយនូវបទបញ្ជាដល់មន្ត្រីនគរបាលទាំងអស់ថា នគរបាលមិនត្រូវធ្វើការចាប់ខ្លួន ឬឃុំខ្លួនកម្មករសិប្បកម្មផលិតឥដ្ឋ ដោយសារតែមិនសងបំណុលឬប៉ុនបងចាកចេញពីសិប្បកម្មនោះទេ។

រាជរដ្ឋាភិបាលគួរផ្សព្វផ្សាយនូវប្រកាសស្តីពីការហាមឃាត់លើការផ្តល់ប្រាក់ឈ្នួលតាមចំនួនផលិតផល ហើយធានាឲ្យមានការផ្តល់ប្រាក់ឈ្នួលអប្បបរមាទាំងនៅរដូវវស្សា និងរដូវប្រាំង។

រាជរដ្ឋាភិបាលត្រូវធានាការអនុវត្តតាមច្បាប់ជាតិ និងអន្តរជាតិឲ្យបានពេញលេញក្នុងការលុបបំបាត់ពលកម្មកុមារ។

រាជរដ្ឋាភិបាលគួរផ្តល់ថវិកាគ្រប់គ្រាន់ដើម្បីធានាថា មន្ត្រីអធិការកិច្ចការងារបំពេញតួនាទីបានពេញលេញ ដែលអាចឃ្លាំមើលនិងស៊ើបអង្កេតលើករណីពលកម្មកុមារ និងធ្វើការដាក់ទោសសមស្របដូចមានចែងនៅក្នុងច្បាប់ស្តីពីការងារ និងប្រកាសពាក់ព័ន្ធផ្សេងទៀត។

រាជរដ្ឋាភិបាលគួរបង្គាប់ឲ្យមានការផ្តល់អាទិភាពនៃការចុះធ្វើអធិការកិច្ចដោយមន្ត្រីអធិការកិច្ចការងារចំពោះសិប្បកម្ម/ឧស្សាហកម្មដែលប្រកបដោយគ្រោះថ្នាក់ ដូចជាសិប្បកម្មផលិតឥដ្ឋ។

រាជរដ្ឋាភិបាលគួរធ្វើការជាមួយតំណាងរបស់វិស័យសំណង់ឯកជននិងសហជីព ហើយសម្រេចនូវតម្លៃឥដ្ឋគោលដែលបង្ហាញពីថ្លៃដើមពិតនៃការផលិត ជាពិសេសប្រាក់បៀវត្សរ៍របស់កម្មករ។

## ►►► ចំពោះរដ្ឋាភិបាលបរទេស និងអ្នកតំណាងរបស់ខ្លួននៅកម្ពុជា

នៅពេលជជែកជាមួយមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលបរទេសគួរលើកឡើងអំពីក្ដីកង្វល់ ចំពោះបញ្ហាការបញ្ចាំខ្លួនដោះបំណុលនិងពលកម្មកុមារក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា ហើយស្នើដល់រាជរដ្ឋាភិបាលឲ្យចាត់វិធានការដើម្បីលុបបំបាត់បញ្ហាទាំងពីរនេះ។

រដ្ឋាភិបាលបរទេសគួរលើកកម្ពស់ការយល់ដឹងដល់វិនិយោគិនបច្ចុប្បន្ននិងអនាគត ដែលមកពីប្រទេសរបស់ខ្លួន អំពីបញ្ហាការបញ្ចាំខ្លួនដោះបំណុលនិងពលកម្មកុមារ។

រដ្ឋាភិបាលបរទេសគួរពង្រឹងយន្តការច្បាប់ដោយឲ្យក្រុមហ៊ុនឯកជនមានការទទួលខុសត្រូវ ដូចជាការចុះបញ្ជី ឬដំណើរការនៅក្នុងប្រទេសរបស់ខ្លួន ចំពោះការប្រើប្រាស់ការបញ្ចាំខ្លួនដោះបំណុលនិងពលកម្មកុមារទោះជាស្ថិតនៅផ្នែកណានៃចង្វាក់ផលិតកម្មក៏ដោយ។

រដ្ឋាភិបាលបរទេសគួរសហការជាមួយវិស័យឯកជននិងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្កើតកម្មវិធីទទួលស្គាល់ ចំពោះសិប្បកម្មផលិតឥដ្ឋណាដែលបានលុបបំបាត់ការបញ្ចាំខ្លួនដោះបំណុលនិងពលកម្មកុមារ៕



ក្មេងប្រុសកំពុងអូសរទេះដឹកឥដ្ឋឆៅដែលទើបនឹងធ្វើរួច

www.licadho-cambodia.org